ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

សៀវភៅទស្សនាវដ្ដីចេញផ្សាយរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់ ១២

ខែ ១១

កុង្សីយ៍សេនាបតីបានអនុញ្ញាតហើយ
សម្ដេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

ភ្នំពេញ
ការផ្សាយរបស់ព្រះរាជបណ្ណាល័យ
ព. ស. ២៤៨៣
គ. ស. ១៩៤០

ល័:09

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

សៀវភៅទស្សនាវដ្ដីចេញផ្សាយរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់ ១២

ខែ ១១

កុងស៊ីយ៍សេនាបតីបានអនុញ្ញាតហើយ
សម្ដេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

ភ្នំពេញ
ការផ្សាយរបស់ព្រះរាជបណ្ណាល័យ
ព. ស. ២៤៨៣
គ. ស. ១៩៤០

## សេចក្តីជូនដំណឹង

# អំពីទស្សនាវដ្តីកម្ពុជសុរិយា

ទស្សនាវដ្តីកម្ពុជសុរិយានេះ បានចេញផ្សាយរឿងរ៉ាវទាំងគតិលោក គតិធម៌ ដើម្បីចែកជូនដល់ញាតិជាតិខ្មែរមើល ដោយដំឡៃយ៉ាងថោកបំផុតឥតយកចំណេញ សព្វថ្ងៃនេះគិតត្រឹម ១ ឆ្នាំ ៤ រៀលប៉ុណ្ណោះ តែដល់ទៅឆ្នាំ ១៩៤១ ទស្សនាវដ្តីនឹងនៅទ្រាំទ្រតាមដំឡៃដដែលនេះទៀតពុំបានគោងតែគិតដំឡើងថ្លៃឡើងទៀតខ្លះជា ១ ឆ្នាំ ៦ រៀល ៥០ សេន ចំនួនសៀវភៅ ១២ ក្បាលក្នុង ១ ឆ្នាំ ។ ដំឡៃនេះ គិតត្រឹមតែរួចខ្លួនមិនមែនយកចំណេញទេ ។

អស់លោក-អ្នកគង់ជ្រាបច្បាស់ហើយថា សព្វថ្ងៃនេះមិនថាតែអ្វីៗទេ សូម្បីតែឡើងថ្លៃគ្រប់ចំពូក រហូតដល់ក្រដាសសម្រាប់បោះពុម្ពទស្សនាវដ្តីនេះក៏ឡើងថ្លៃមួយជាបីជាបួន ថែមទាំងរកទិញបានដោយកម្រផង ។ កាលបើលោក-អ្នកបានជ្រាបសេចក្តីពិតដូច្នេះហើយ ក៏មិនត្រូវមានចិត្តធុញទ្រាន់នឹងដំឡៃដែលត្រូវដំឡើងបន្ថែមបន្តិចបន្តួចនេះទេ ។ មួយវិញទៀត បើយើងពិនិត្យមើលរឿងផ្សេងៗ ដែលមានចុះផ្សាយកាលខែក្នុងឆ្នាំ ១៩៤០ នេះជាដើមទៅ គង់យល់ថារឿងនីមួយៗមានដំឡៃថ្លៃថ្នូរលើសថ្លៃជាច្រើនលើសលប់គណនា ដូចពង្សាវតាររបស់នានាប្រទេសឬពង្សាវតារ

លោកដែលយើងចុះផ្សាយកល់ខែនេះ  នាំឲ្យលោក-អ្នកមើលទស្សនាវដ្ដីកើតចំណេះចេះដឹងយ៉ាងធំទូលាយ  ហាក់ដូចជាលោក-អ្នកមានអាយុកប់ទាំងពាន់ៗឆ្នាំ  ហើយបានធ្វើដំណើរទៅកាន់នានាប្រទេសដោយខ្លួនឯង ហើយបានដឹងបានឮរឿងរ៉ាវប្លែកៗក្នុងប្រទេសនោះៗយ៉ាងអស្ចារ្យ ។ ចំណែកខាងគតិធម៌វិញ  ក៏បានចុះផ្សាយរឿងពុទ្ធសាសនាដែលមានក្នុងនានាប្រទេសដែលកាន់ពុទ្ធសាសនា  តាំងអំពីសម័យបុរាណដរាបមកដល់សម័យបច្ចុប្បន្ននេះ  ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញារបស់ពុទ្ធសាសនិកជនខ្មែរជាតិ  ព្រមទាំងគំនិតយោបល់របស់ពួកអ្នកប្រាជ្ញខ្លះរូបដែលនិយាយអំពីពុទ្ធសាសនារបស់យើងនេះផង ។

ហេតុដូច្នេះ  អស់លោកដែលចុះឈ្មោះជាវមកហើយគួរតែចុះឈ្មោះជាវក្នុងឆ្នាំមុខតទៅទៀត  អស់លោក-អ្នកដែលមិនទាន់ចុះឈ្មោះជាវទេ កាលបើបានជ្រាបដំណឹងនេះហើយគួរតែនាំគ្នាមកចុះឈ្មោះជាវឲ្យកាន់តែច្រើនឡើង  ហើយជួយផ្សាយដំណឹងនេះតៗគ្នាទៅទៀតផង  ដើម្បីជួយជ្រោមជ្រែងអក្សរសាស្ត្រខ្មែរនិងពុទ្ធសាសនាឲ្យបានបិតថេរ និងចំរើនរុងរឿងនៅក្នុងកម្ពុជានេះអស់កាលជាអង្វែងតរៀងទៅ ។

លោកដែលយើងចុះផ្សាយរាល់ខែនេះ នាំឲ្យលោក-អ្នកមើលទស្សនាវដ្ដីកើតចំណេះចេះដឹងយ៉ាងធំទូលាយ ហាក់ដូចជាលោក-អ្នកមានអាយុរាប់តាំងពាន់ៗឆ្នាំ ហើយបានធ្វើដំណើរទៅកាន់នានាប្រទេសដោយខ្លួនឯង ហើយបានដឹងបានឮរឿងរ៉ាវប្លែកៗក្នុងប្រទេសនោះៗយ៉ាងអស្ចារ្យ ។ ចំណែកខាងគតិធម៌វិញ ក៏បានចុះផ្សាយរឿងពុទ្ធសាសនាដែលមានក្នុងនានាប្រទេសដែលកាន់ពុទ្ធសាសនា តាំងអំពីសម័យបុរាណដរាបមកដល់សម័យបច្ចុប្បន្ននេះ ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញារបស់ពុទ្ធសាស-និកជនខ្មែរជាតិ ព្រមទាំងគំនិតយោបល់របស់ពួកអ្នកប្រាជ្ញឧរុបដែលនិយាយអំពីពុទ្ធសាសនារបស់យើងនេះផង ។

ហេតុដូច្នេះ អស់លោកដែលចុះឈ្មោះជាវមកហើយគួរតែចុះឈ្មោះជាវក្នុងឆ្នាំមុខតទៅទៀត អស់លោក-អ្នកដែលមិនទាន់ចុះឈ្មោះជាវទេ កាលបើបានជ្រាបដំណឹងនេះហើយគួរតែនាំគ្នាមកចុះឈ្មោះជាវឲ្យកាន់តែច្រើនឡើង ហើយជួយផ្សាយដំណឹងនេះតៗគ្នាទៅទៀតផង ដើម្បីជួយជ្រោមជ្រែងអក្សរសាស្ត្រខ្មែរនិងពុទ្ធសាសនាឲ្យបានឋិតថេរ និងចំរើនរុងរឿងនៅក្នុងកំឡុងក្រុងកម្ពុជានេះអស់កាលជាអង្វែងតរៀងទៅ ។

# បដិទិន ឆ្នាំ ១៩៤១

ទុកជាក្រដាសឡើងថ្លៃយ៉ាងសំបើមក៏ដោយ ពុទ្ធសាសនបណ្ឌិត្យក៏នៅតែចំរើនបោះពុម្ពបដិទិនផ្សាយដល់មហាជនខ្មែរ ដូចក្នុងឆ្នាំមុនៗរៀងមក ហើយលក់ដោយដំឡៃយ៉ាងសមគួរជាបំផុត គឺបដិទិនបន្ទះក្រដាសរឹង ១ សន្លឹក ២០ សេន បដិទិនបត ១ ដំឡៃ ៦៥ សេន ។

ខណៈនេះកំពុងបោះពុម្ព ដល់ដាច់ខែណូវ៉ែម្ប្រ៍ ឆ្នាំ ១៩៤០ នេះ សូមអញ្ជើញទៅទិញតាមត្រូវការ ។ មានលក់ចំណាយនៅព្រះរាជបណ្ណាល័យ ស្ថានីយរទេះភ្លើងភ្នំពេញនិងហាងពុម្ពនគរវត្ត ។

# បញ្ជីរឿង

ទំព័រ


១— អំពីគោលសំខាន់ៗនៃព្រះពុទ្ធសាសនា សំរាប់ពួកមនុស្សទំនើបថ្មី របស់លោកគូមោម៉ុតស៊ី . . . . . . . . . . . . . . . . . . . . . ៣

២— និយាយអំពីការបួសខ្មែរ ស្រង់យកនឹងប្រែចេញពីវចនានុក្រមរបស់លោកគីយ៉េត . . . . . . . . . . . . . . . . . . . . . . ១១

៣— អំពីពង្សាវតារប្រទេសក្រិក ស្រង់នឹងរៀបរៀងតាមគោលបារាំងផ្សេង ៗ នៃប្រវត្តិសាស្ត្រសាកល ( តនឹងចប់ ) . . . . . . . . . . . . . . ១៩

៤— អនាមយកថា របស់ទេវរង្សី (មានត) . . . . . . . . . . . . ៣១

៥— ប្រវត្តិនៃមហាបុរស តាំងពីដើមរៀងៗមក (មានត) . . . . . . . . ៤៥

៦— ពុទ្ធប្បវត្តិតាមគំនូរបិទ (មានត) . . . . . . . . . . . . . . ៥១

៧— ប្រវត្តិមីលរេប៉ះ ប្រែចេញពីទីបេតាំងមកជាភាសាបារាំងសែស របស់លោកស៊ុក បាកូត៍ (តនឹងចប់) . . . . . . . . . . . . . . . . . ៥៥

៨— ដំណឹងផ្សេងៗ . . . . . . . . . . . . . . . . . . . . . . . ៥៩

៩— ប្រជុំពាក្យកាព្យខ្មែរភាគទី ៤ របស់រក្សាភិរម្យអ៊ួង (ត) . . . . . . . . . ៦៣


## រូបក្រៅរឿង


តាមគំនូរបិទ
១— អំពីការបូជាជីខ្សាប់ . . . . . . . . . . . . . . . . . . ១
២— អំពីការទ្រង់បដិមបិណ្ឌបាត . . . . . . . . . . . . . . . ៩
៣— ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រទានបដិមឱវាទ . . . . . . . . . . ១៧
៤— អំពីទ្រង់ចូលបរិនិព្វាន . . . . . . . . . . . . . . . . ២៩
៥— អំពីសេចក្តីសៅសោក . . . . . . . . . . . . . . . . ៤៣

គំនូរទីបេតាំង
៦— មីលរេប៉ះត្រឡប់ជាមានរូបកាយជាសមណៈប្រាកដឡើងវិញទៀត . . . . . . . . . . . . . . . . . . . . . ៥៣

# TABLE DES MATIÈRES


| | Pages |
|---|---|
| 1° Le Bouddhisme au Japon, extrait du livre de Mr. TOMOMATSU (fin) | 3 |
| 2° Notes au sujet de l'architecture Khmère | 11 |
| 3° Histoire de la Grèce, extrait de divers documents de l'histoire universelle | 19 |
| 4° ANĀMAYAKATHA par KHÉMARARANSĪ (suite) | 31 |
| 5° Histoire de la Pensée à travers les âges (suite) | 45 |
| 6° La Vie du Bouddha d'après des documents chinois (suite) | 51 |
| 7° La Vie de Milarépa, traduit du Tibétain en Français par JACQUES BACOT (suite) | 55 |
| 8° Informations diverses | 59 |
| 9° Recueil de Poèmes Cambodgiens; 4° partie, par RAK-PHIROM UONG (suite et fin) | 63 |


HORS TEXTES :


| | | |
|---|---|---|
| Dessins chinois | 1° L'offrande de sable | 1 |
| | 2° L'invitation au dernier repas | 9 |
| | 3° Les dernières recommandations du Bouddha | 17 |
| | 4° Le Nibbana | 29 |
| | 5° Les lamentations | 43 |
| Peinture tibétaine | 6° MILARÉPA apparaît avec son corps mystique | 53 |



៤— អំពីការបូជាដីល្បាប់ ។

# គោលធំៗរបស់ព្រះពុទ្ធសាសនា

# សម្រាប់មនុស្សសម័យថ្មី

ពាក្យនេះជាឈ្មោះសៀវភៅមួយដែលគេបានប្រែមកពីសៀវភៅភាសាជប៉ុន ។ លោកអ្នកតែងរឿងនេះឈ្មោះ អនតៃ តូមោម៉ុតស៊ុ (Entai Tomomatsu) ក្នុងអារម្ភកថានៃសៀវភៅនោះនិយាយសរុបសេចក្តីថា លោកអ្នកតែងប្រឹងសំដែងឲ្យឃើញវិធីពុទ្ធសាសនាប្រព្រឹត្តទៅក្នុងចិត្តគំនិតប្រចាំរូបមនុស្សសម័យឥឡូវនេះ ។ តាំងអំពីកាលមិនប៉ុន្មានឆ្នាំមកនេះ មានការប្រែប្រួលយ៉ាងធំកើតឡើងនៅទ្វីបឧរុប ហើយគេបានរៀបចំចិត្តគំនិតដំរូវមកលើពុទ្ធសាសនា ព្រោះប្រជាជនជាតិឧរុបទាំងឡាយត្រូវការសេចក្តីពន្យល់យ៉ាងត្រឹមត្រូវនឹងសេចក្តីពន្យល់យ៉ាងជ្រាលជ្រៅអំពីលទ្ធិពុទ្ធសាសនានេះ ។ ពួកឧរុបគិតថា មិនមានលទ្ធិដទៃក្រៅពីលទ្ធិពុទ្ធសាសនាដែលជាលទ្ធិបរិបូណ៌ដោយអាហារចំណីសម្រាប់ចិត្ត ដែលគេមានសេចក្តីត្រូវការណាស់ក្នុងខណៈដែលលោកកំពុងរំភើបរញ្ជួយនេះ ។ ការបានមកជួបប្រទះនឹងលទ្ធិពុទ្ធសាសនា ទើបគេនាំគ្នាសរសើររឿងព្រះពុទ្ធសាសនាដែលមាននៅក្នុងចិត្តគំនិតរបស់ពួកបូព៌ាប្រទេស នឹងប្រចាំចិត្តគំនិតរបស់ពុទ្ធសាសនិកជនក្នុងសម័យសព្វថ្ងៃនេះ ។

ទោះបីនៅប្រទេសជប៉ុន ជាប្រទេសប្រកាន់របៀបទំនើបថ្មីតាមជាតិឧរុបក៏ដោយ ក៏នៅមាននិស្សិត (កូនសិស្ស) ១០.០០០ ដែលប្រតិបត្តិ

តាមច្បាប់ពុទ្ធសាសនា ដែលមាននៅក្នុងសាលាមហាវិទ្យាល័យពុទ្ធសាសនានានា និងនៅតាមសាលាកុមារកុមារីផ្សេងៗ ដែលពុទ្ធសាសនិកជនជាអ្នកត្រួតត្រាចាត់ចែង ហើយមានប្រូក្រាមបង្រៀនលទ្ធិសាសនាក្នុងសាលាអស់នោះផង ។

នៅប្រទេសជប៉ុន មានចំនួនលោកសង្ឃពុទ្ធសាសនាប្រហែល ១០០.០០០ រូប ក្នុងចំនួននេះមានលោកសង្ឃខ្លះមានអនុភាពផ្សាយសីលធម៌ទៅក្នុងសមាគមប្រជាជនជប៉ុនយ៉ាងធំទូលាយផង ព្រោះកិច្ចសំខាន់របស់ពុទ្ធសាសនិកជនតែងខំប្រឹងប្រែងធ្វើការដើម្បីជាប្រយោជន៍នឹងសេចក្តីចំរើនដល់ចិត្តគំនិតរបស់ប្រជាជនទូទៅ ។ ព្រះពុទ្ធសាសនារបស់ជប៉ុននេះ យើងមើលឃើញមានសេចក្តីចំរើនរុងរឿងល្អ បើទុកជាមើលឃើញថែបទ្រង់ទ្រាយពុទ្ធសាសនាជាន់ដើមបាត់សាបសូន្យទៅព្រមទាំងបែបផែនវត្តអារាមជាន់ចាស់របស់ជប៉ុនផងក៏ដោយ ពុទ្ធសាសនានៅប្រទេសជប៉ុនក៏មិនមែនត្រឹមមានជីវិតរស់នៅប៉ុណ្ណោះទេ ថែមទាំងឧត្តមគតិរបស់ពុទ្ធសាសនាក៏គង់ទ្រង់នៅតាមកាលសម័យផង ។

ពួកអ្នកប្រាជ្ញពុទ្ធសាសនាជាតិជប៉ុននោះមិនមែនគ្រាន់តែជាអ្នកប្រតិបត្តិតាមគោលពុទ្ធសាសនាកប់មកដោយពាន់ៗឆ្នាំប៉ុណ្ណោះទេ គឺគេខំប្រឹងសិក្សានិងធ្វើតាមបែបវិទ្យាសាស្ត្រទំនើបថ្មី ហើយរួមកិច្ចការជាមួយនឹងពួកអ្នកប្រាជ្ញរូបបានស្រួលឥតមានទាស់ទែងខ្វែងគំនិតគ្នាឡើយ ។

តាមច្បាប់ពុទ្ធសាសនា ដែលមាននៅក្នុងសាលាមហាវិទ្យាល័យពុទ្ធសាសនានានា និងនៅតាមសាលាកុមារកុមារីផ្សេងៗ ដែលពុទ្ធសាសនិកជនជាអ្នកត្រួតត្រាចាត់ចែង ហើយមានប្រូក្រាមបង្រៀនលទ្ធិសាសនាក្នុងសាលាអស់នោះផង ។

នៅប្រទេសជប៉ុន មានចំនួនលោកសង្ឃពុទ្ធសាសនាប្រហែល ១០០.០០០ រូប ក្នុងចំនួននេះមានលោកសង្ឃខ្លះមានអានុភាពផ្សាយសីលធម៌ទៅក្នុងសមាគមប្រជាជនជប៉ុនយ៉ាងធំទូលាយផង ព្រោះកិច្ចសំខាន់របស់ពុទ្ធសាសនិកជនតែងខំប្រឹងប្រែងធ្វើការដើម្បីជាប្រយោជន៍នឹងសេចក្តីចំរើនដល់ចិត្តគំនិតរបស់ប្រជាជនទូទៅ ។ ព្រះពុទ្ធសាសនារបស់ជប៉ុននេះ យើងមើលឃើញមានសេចក្តីចំរើនរុងរឿងល្អ បើទុកជាមើលឃើញបែបទ្រង់ទ្រាយពុទ្ធសាសនាជាន់ដើមបាត់សាបសូន្យទៅព្រមទាំងបែបផែនវត្ថុអារាមជាន់ចាស់របស់ជប៉ុនផងក៏ដោយ ពុទ្ធសាសនានៅប្រទេសជប៉ុនក៏មិនមែនត្រឹមមានជីវិតរស់នៅប៉ុណ្ណោះទេ ថែមទាំងឧត្តមគតិរបស់ពុទ្ធសាសនាក៏គង់ទ្រង់នៅតាមកាលសម័យផង ។

ពួកអ្នកប្រាជ្ញពុទ្ធសាសនាជាតិជប៉ុននោះមិនមែនគ្រាន់តែជាអ្នកប្រតិបត្តិតាមគោលពុទ្ធសាសនាកប់មកដោយពាន់ៗឆ្នាំប៉ុណ្ណោះទេ គឺគេខំប្រឹងសិក្សាទាំងធ្វើតាមបែបវិទ្យាសាស្ត្រទំនើបថ្មី ហើយរួមកិច្ចការជាមួយនឹងពួកអ្នកប្រាជ្ញរូបបានស្រួលឥតមានទាស់ទែងខ្វែងគំនិតគ្នាឡើយ ។

ពួកអ្នកស្រុកទិសខាងលិច (សំដៅប្រទេសឱរុប) កំពុងនៅក្នុងសម័យរំភើបញ័របញ្ញ័រ តែងប្រទះនឹងសេចក្ដីព្រួយ សេចក្ដីបារម្ភយ៉ាងខ្លាំង ទើបគេនាំគ្នាងាកមករកព្រះពុទ្ធសាសនា ដោយគិតថា លទ្ធិនេះហើយនឹងជួយបំពេញរបស់ដែលគេនៅខ្វះខាត ៗ នៅប្រទេសអល្លឺម៉ាញ ប្រទេសបារាំងសែស និងប្រទេសអង់គ្លេស ពុទ្ធសាសនិកជនក្នុងប្រទេសអស់នេះគេតែងបានត្រុំដំណាំងកល់ ៗ អាទិត្យថា នៅក្រុងឡុនដនគេតែងទេសនាប្រកាសព្រះពុទ្ធសាសនាដល់ប្រជាជនអង់គ្លេសមិនដែលដាច់ខាន ៗ មហានគរបារាំងសែសក៏យល់ច្បាស់ឃើញប្រយោជន៍ខាងវេទនាព្រះពុទ្ធសាសនាណាស់ដែរ ហើយព្រះពុទ្ធសាសនាក៏នឹងផ្សាយចេញទៅក្នុងប្រជាជនបារាំងសែសដោយសារលំអខាងវេទនានេះឯង ប៉ុន្តែមិនមែនដោយសារគ្រាន់តែចង់ដឹងចង់ឃើញប៉ុណ្ណោះទេ ឬពីព្រោះតែមហានគរបារាំងសែសស្គាល់រាប់អានប្រទេសឥណ្ឌូស៊ីននេះទេ គឺដោយមានចិត្តស្រឡាញ់អារ្យធម៌របស់ព្រះពុទ្ធសាសនា ដោយស្រឡាញ់និស្ស័យប្រកបដោយបរមត្ថវិជ្ជាសម្រាប់អប់រំចិត្តផ្ចាល់ខ្លួននឹងដោយសេចក្ដីត្រូវការផ្ដើមធ្វើនេះ គឺការចំរើនភាវនាកម្មជាកិច្ចប្រតិបត្តិដែលខានពុំបានតាមរបៀបពុទ្ធសាសនា ៗ

ក្រោយមហាសង្គ្រាមក្នុងឆ្នាំ ១៩១៤ មក ពួកជនជាតិឱរុបបានភ្ញាក់ខ្លួនរាល់គ្នា ហើយងាកទៅរកបរមត្ថវិជ្ជាមួយដែលបដិសេធ (អត្តា) គេ

យល់ថាបរមត្ថវិជ្ជាបែបនេះជាវិជ្ជាមួយសម្រាប់លើកឡើងដំកល់ដំកើងខានពុំបានឡើយ ។ ព្រះនិព្វានជាផលចិត្តប្រកបដោយបរមសុខកើតឡើងដោយសារមនុស្សយើងព្យាយាមត្រិះរិះបានសម្រេចមកដោយខ្លួនឯង ។

ក្នុងការសិក្សាឲ្យស្គាល់ព្រះពុទ្ធសាសនាច្បាស់លាស់នេះ ពួកជាតិឧរុបពិនិត្យឃើញថា លទ្ធិពុទ្ធសាសនាព្រមទទួលក៏ប់រង សេចក្ដីពិតដែលកើតមានឡើងពីផលនៃវិជ្ជាការរបស់មនុស្ស ដែលខំប្រឹងប្រែងធ្វើឲ្យកើតឡើងដោយទំនើងខ្លួនឯង ។ ពួកឧរុបពិនិត្យឃើញថា លទ្ធិពុទ្ធសាសនាបរមបុកណានេះបដិសេធមិនយល់ព្រមតាមគតិដែលថា ព្រលឹងរបស់មនុស្សជារបស់រស់នៅជានិច្ចនិរន្តរមិនប្រែប្រួល ។ ហើយគេរកឃើញថា លទ្ធិសាសនានេះគ្មាននិយាយអាងពីព្រះម្ចាស់សួគ៌ទេ ទើបគេនាំគ្នាសិក្សាលទ្ធិពុទ្ធសាសនា ដែលមានគេនិយាយជារឿយ ៗ ជាទំនងថា "មនុស្សយើងនឹងបានជាពុទ្ធ" ពាក្យនេះសំដៅសេចក្ដីថា មនុស្សយើងគោងខំប្រឹងព្យាយាមដុសខាត់ចិត្តគំនិតឲ្យស្អាតបរិសុទ្ធឡើង នេះហើយជាឧបាយដ៏ធំទូលាយ មិនមានខេត្តកំណត់ដែលអាចនាំឲ្យចំរើនដល់លក្ខណៈរបស់មនុស្សជាតិ ។

បែបរបនាពុទ្ធសាសនានេះធ្វើឲ្យពួកជាងរបនាជាតិឧរុបយកចិត្តទុកដាក់ជាតន្ទឹករំលងពុំបាន មិនមែនគ្រាន់តែចង់ដឹងប៉ុណ្ណោះទេ តែដោយ

យល់ថាបរមត្ថវិជ្ជាបែបនេះជាវិជ្ជាមួយសម្រាប់លើកឡើងដំកល់ដំកើង ខាងពុំបានឡើយ ។ ព្រះនិព្វានជាផលចិត្តប្រកបដោយបរមសុខកើតឡើងដោយសារមនុស្សយើងព្យាយាមត្រិះរិះបានសម្រេចមកដោយខ្លួនឯង ។

ក្នុងការសិក្សាឲ្យស្គាល់ព្រះពុទ្ធសាសនាច្បាស់លាស់នេះ ពួកជាតិអឺរុបពិនិត្យឃើញថា លទ្ធិពុទ្ធសាសនាព្រមទទួលរ៉ាប់រង សេចក្តីពិតដែលកើតមានឡើងពីផលនៃវិជ្ជាការរបស់មនុស្ស ដែលខំប្រឹងប្រែងធ្វើឲ្យកើតឡើងដោយខំនឹងខ្លួនឯង ។ ពួកអឺរុបពិនិត្យឃើញថា លទ្ធិពុទ្ធសាសនាបរមបុរាណនេះបដិសេធមិនយល់ព្រមតាមគតិដែលថា ព្រលឹងរបស់មនុស្សជារបស់រស់នៅជានិច្ចនិរន្តរមិនប្រែប្រួល ៗ ហើយគេរកឃើញថាលទ្ធិសាសនានេះគ្មាននិយាយអាងពីព្រះម្ចាស់សួគ៌ទេ ទើបគេនាំគ្នាសិក្សាលទ្ធិពុទ្ធសាសនា ដែលមានគេនិយាយជារឿយ ៗ ជាទំនងថា “មនុស្សយើងនឹងបានជាពុទ្ធ” ពាក្យនេះសំដៅសេចក្តីថា មនុស្សយើងគោងខំប្រឹងព្យាយាមដុសខាត់ចិត្តគំនិតឲ្យស្អាតបរិសុទ្ធឡើង នេះហើយជាឧបាយដ៏ធំទូលាយ មិនមានខេត្តកំណត់ដែលអាចនាំឲ្យចំរើនដល់លក្ខណៈរបស់មនុស្សជាតិ ។

បែបរបស់ពុទ្ធសាសនានេះធ្វើឲ្យពួកជាងរបស់ជាតិអឺរុបយកចិត្តទុកដាក់ជាពន្លឹករំលងពុំបាន មិនមែនគ្រាន់តែចង់ដឹងប៉ុណ្ណោះទេ តែដោយ

ជាប់ចិត្តស្រឡាញ់រូបគំនូរឬរូបចំឡាក់ដែលគេធ្វើជាសំណាករចនាអស់នោះ ៗ ពួកជនជាតិអឺរ៉ុបទាប់ក៏ទឹកជាប់ចិត្តនឹងលក្ខណៈរបស់ព្រះពុទ្ធជាម្ចាស់នឹងសទ្ធិភាពយ៉ាងពេញលេញគ្រប់ ៗ ចំណែក ដែលជាបែបរចនារបស់ព្រះពុទ្ធសាសនា ទើបនាំគ្នាមកពិនិត្យប្រតិបត្តិតាមវិជ្ជាខាងផ្លូវចិត្តរបស់ព្រះពុទ្ធសាសនាដែលជាលទ្ធិមិនចេះស្លាប់ ហើយជាលទ្ធិចូលជ្រៀតជ្រែកក្នុងចិត្តគំនិតរបស់មនុស្សទំនើបថ្មី ៗ មុខក្រសួងរបស់យើងដែលជាមនុស្សសម័យថ្មីនេះគោងតែរៀបចំគំនិតគិតគូរឲ្យលូតលាស់ចំរើនឡើង (ទើបត្រូវនឹង) ព្រោះព្រះពុទ្ធសាសនាកើតក្នុងសមាគមតណ្ហាសម័យបុរាណដែលគេបានរក្សាទុកនូវរបៀបបែបបុរាណ ដែលជាសម័យមិនត្រូវការប្រាក់កាសប៉ុន្មានផង តែនឹងនាំយកមកប្រើការក្នុងសមាគមសម័យឥឡូវនេះឲ្យសព្វគ្រប់ពុំបានក៏មិនមែនដែរ ៗ តាមដោយពិតនោះព្រះពុទ្ធជាមនុស្ស ក៏មិនមានប្រែប្រួលប្លែកពីមនុស្សក្នុងសម័យយើងឥឡូវនេះទេ គឺជាព្រះពុទ្ធនឹងមនុស្សយើងក៏ជាមនុស្សដូចគ្នាដែរ មនុស្សរមែងមានជំនឿនឹងមនុស្សផងគ្នាជានិច្ច ក្នុងសម័យពុទ្ធកាលក៏ធ្វើឲ្យយើងជឿរឿងរ៉ាវជាអនេកនេះដែរ ទាំងនេះមិនមែនធ្វើឲ្យបាត់ដំឡៃរឿងរ៉ាវក្នុងសម័យសព្វថ្ងៃនេះទេ ៗ តាមដោយពិតនោះ តាំងពីដើមមក ព្រះពុទ្ធសាសនាមិនមែនគ្របក្រសោបចំពោះរឿងនិមួយៗទេ គឺបានត្រាទុក

ច្រើនប្រការណាស់ ទើបមានកំឡាំងអានុភាពតាំងនៅក្នុងសាកលលោកនេះ ហើយប្រកបដោយហេតុផលដ៏ត្រឹមត្រូវជាបំផុត ទើបយល់ថា ចរិតនិស្ស័យមនុស្សរបស់ព្រះពុទ្ធជាម្ចាស់នេះត្រូវតែមានអានុភាពដ៏ធំទូលាយដើម្បីរក្សាទុកនូវរបៀប(សម័យថ្មី) កសិណសាក្សីរបស់ពុទ្ធសាសនានេះក៏គឺការគង់ទ្រង់រហូតមកជាវេលា ២.៥០០ ឆ្នាំនេះក៏នៅតែមានសេចក្ដីចំរើនដ៏រឹងប៉ឹងម៉ឹងម៉ាត់នៅក្នុងលោក ដែលជ្រាបចូលទៅនៅក្នុងចិត្តគំនិតរបស់មនុស្សក្នុងសម័យនៃយើងសព្វថ្ងៃនេះ ។

ច្រើនប្រការណាស់ ទើបមានកំឡាំងអានុភាពតាំងនៅក្នុងសាកលលោក នេះ ហើយប្រកបដោយហេតុផលដ៏ត្រឹមត្រូវជាបំផុត ទើបយល់ថា ចរិតនិស្ស័យមនុស្សរបស់ព្រះពុទ្ធជាម្ចាស់នេះត្រូវតែមានអានុភាពដ៏ធំទូលាយ ដើម្បីរក្សាទុកនូវរបៀប(សម័យថ្មី) កសិណសាក្សីរបស់ពុទ្ធសាសនានេះ ក៏គឺការគង់ទ្រង់រហូតមកជាវេលា ២.៥០០ ឆ្នាំនេះក៏នៅតែមានសេចក្ដីចំរើន ដ៏រឹងប៉ឹងម៉ឺងម៉ាត់នៅក្នុងលោក ជ្រួតជ្រាបចូលទៅនៅក្នុងចិត្តគំនិតរបស់ មនុស្សក្នុងសម័យនៃយើងសព្វថ្ងៃនេះ ។



៤១— អំពីការទទួលចង្ហាន់ចុងក្រោយបង្អស់ ។

# អំពីរចនាខ្មែរ

ក្នុងសព្វវចនាធិប្បាយបារាំងសែសមួយ របស់លោកគីយ៉េត មានសេចក្ដីអធិប្បាយអំពីវិជ្ជារចនាខ្មែរដូច្នេះថា "បណ្ដាបុរាណវត្ថុដ៏ល្អះល្អថ្លៃថ្លាដែលមានសេសសល់នៅក្នុងស្រុកខ្មែរ បានតាំងសាងមកដោយប្រ-ជាជនជាតិខ្មែរ ដែលខ្មែរបានទទួលជាដំណាលមកផ្ទាល់ខ្លួន តាមបែបរចនាហិណ្ឌូ ។ គ្រឿងបុរាណវត្ថុអស់នោះគេបានកសាងមកក្នុងរវាង ព. ស. ១២៤៣ នឹង ព. ស. ១៨៤៣ ។ យើងនឹងរៀបរាប់អំពីពួកបុរាណវត្ថុនៅអង្គរដែលល្បីល្បាញបំផុត ទាំងខាងអង្គរធំ ទាំងខាងអង្គរវត្ត" ។

បែបរចនាខ្មែរដែលលូតលាស់បែកមែកធាងមានផ្លែផ្កា ជិតមកដល់ពុទ្ធសករាជ ១៩៤៣ នៅទិសខាងជើងឆៀងខាងលិច (ទិសពាយ័ព្យ) ក្នុងស្រុកខ្មែរ រចនានេះក៏ជាប់ទាក់ទងមកពីបែបរចនាហិណ្ឌូ ប៉ុន្តែមានទំ-នងប្លែកជាច្រើនដោយមានបែបរចនារបស់ចាមប្រកបផង (ដែលនៅខាងត្បូងដែនអណ្ណាម) នឹងបែបរចនាថៃ (សៀម) នឹងលាវ នៅត្រង់ដែលមានរចនាបែបចិនក៏មាន ដូចជាអយុធ្យានឹងសុខោថៃ (សុខោទ័យ) ជាដើម ។

បែបសិល្បហត្ថកម្មខ្មែរជាបែបមើលឃើញច្បាស់លាស់ដោយខ្នាតធំទូលាយ ការកែប្រែខ្នាតនឹងបែបសណ្ឋានសន្សឹមៗមានមកជាលំដាប់ វិហារ

ប្រាសាទធំៗ នៅរួមគ្នានៅក្រុមប្រាសាទអង្គរវត្ត (ព.ស. ១៦៤៣) និង នៅទីក្រុងអង្គរធំ ដូចជាបាយ័ន បែបចម្លាក់រចនាធ្វើជាប្រាសាទសុះសាយ ដោយក្បាច់ផ្ចង់ដូចជាគេប៉ាក់ ៗ ជញ្ជាំងសោតទៀតក៏មានជារឿងរ៉ាវស្អក ស្កាស់ ជារូបថ្ងៃដំណាលរឿងរ៉ាវផ្សេងៗ ជារឿងព្រេងជាដើម ៗ ពួក ជាងចម្លាក់ខ្មែរបេះឆ្លាក់បែបភាពផ្សេង ៗ ជាច្រើនយ៉ាងណាស់ មិនឲ្យត្រូវ គ្នាគ្រប់អន្លើ ដូចជាបង្អួចឲ្យឃើញបែបភាពស្រីទេពអប្សរនៅស្ថានសួគ៌ៗ ដោយច្រើនគ្រឿងប្រដាប់ប្រដាផ្សេង ៗ ក៏ប្រែប្រួលណាស់ដែរ ដែលចំ- ឡងយកមកពីស្រុកឥណ្ឌាក៏មាន. មានរូបសត្វគ្រុឌនឹងពស់ឬនាគជាដើម មានចូនកាលយកពីចិន ដូចជារូបសត្វសិង្ហជាដើម ៗ

* * *

·ត្រង់ពាក្យថា ស្រុកខ្មែរ (Cambodge) មានសេចក្តីពន្យល់ដូច្នេះ:

កម្ពុជា ជាអាណាចក្រមួយនៅក្នុងឥណ្ឌូចិន ក្រោមសេចក្តីទំនុកបំរុងរបស់មហានគរបារាំងសែស តាំងអំពីពុទ្ធសករាជ ២៤០៦ (ឥឡូវនេះ ២៤៨៣ គឺ ៧៧ ឆ្នាំនឹងឆ្នាំនេះ) ស្រុកនេះមានទំហំដី ១៧៥.០០០ គីឡូម៉ែត្រក្រឡា ចំនួនមនុស្ស ២.៨០៦.០០០ ក្នុងចំនួននេះមានជាតិអឺរ៉ុប ២.២០០ នាក់ ៗ

ស្រុកនេះនៅត្រង់កន្លែងដីទំនាបរបស់ទន្លេមេគុង តែខ្ពស់ជាងមាត់

ប្រាសាទធំៗ នៅរួមគ្នានៅក្រុមប្រាសាទអង្គរវត្ត (ព.ស. ១៦៤៣) និង នៅទីក្រុងអង្គរធំ ដូចជាបាយ័ន ដែលចម្លាក់រចនាធ្វើជាប្រាសាទសុះសាយ ដោយក្បាច់ថ្នដូចជាគេប៉ាក់ ៗ ជញ្ជាំងសោតទៀតក៏មានជារឿងរ៉ាវស្អក ស្កាស់ ជារូបថ្លែងដំណាលរឿងរ៉ាវផ្សេងៗ ជារឿងព្រេងជាដើម ។ ពួកជាងចម្លាក់ខ្មែរបេះឆ្លាក់បែបភាពផ្សេង ៗ ជាច្រើនយ៉ាងណាស់ មិនឲ្យត្រូវគ្នាគ្រប់អន្លើ ដូចជាចង្អុលឲ្យឃើញបែបភាពស្រីទេពអប្សរនៅស្ថានសួគ៌ៗ ដោយច្រើនគ្រឿងប្រដាប់ប្រដាផ្សេង ៗ ក៏ប្រែប្រួលណាស់ដែរ ដែលចំឡងយកមកពីស្រុកឥណ្ឌាក៏មាន . មានរូបសត្វគ្រុឌនឹងពស់ឬនាគជាដើម មានចួនកាលយកពីចិន ដូចជារូបសត្វសិង្ហជាដើម ។

* * *

ត្រង់ពាក្យថា ស្រុកខ្មែរ (Cambodge) មានសេចក្ដីពន្យល់ដូច្នេះ:

កម្ពុជា ជាអាណាចក្រមួយនៅក្នុងឥណ្ឌូសុីន ក្រោមសេចក្ដីទំនុកបំរុងរបស់មហានគរបារាំងសែស តាំងអំពីពុទ្ធសករាជ ២៤០៦ (ឥឡូវនេះ ២៤៨៣ គឺ ៧៧ ឆ្នាំនឹងឆ្នាំនេះ) ស្រុកនេះមានទំហំដី ១៧៥.០០០ គីឡូម៉ែត្រក្រឡា ចំនួនមនុស្ស ២.៨០៦.០០០ ក្នុងចំនួននេះមានជាតិអឺរុប ២.២០០ នាក់ ។

ស្រុកនេះនៅត្រង់កន្លែងដីទំនាបរបស់ទន្លេមេគង្គ តែខ្ពស់ជាងមាត់

ពាមខាងស្រុកកូសាំងស៊ីន ហើយដីទំនាបធំនោះព័ទ្ធជុំវិញដីខ្ពួលកបដែលនៅខាងកើតនឹងខាងជើង ហើយនឹងដាច់ឃ្លាតពីសមុទ្រ តាមភ្នំក្រវាញនឹងភ្នំដំរី ។ ស្រុកនេះមានទន្លេសាប បាតទន្លេជាដីទាបស្រៀវជាប់ខ្សែទឹកមកដល់ទន្លេមេគង្គ ដែលទឹកទន្លេមេគង្គតែងហូរចាក់ចូលទៅក្នុងទន្លេសាបក្នុងពេលទឹកឡើងហើយហូរធ្លាក់មកទន្លេមេគង្គវិញក្នុងពេលទឹកស្រក ។ តាមមាត់សមុទ្រមានកោះក្នុំក្រមថ្ន អាកាសស្រុកនេះក្ដៅតែសើម (ដោយខ្យល់មុស្សុង) ។ ស្រុកខ្មែរនេះមានព្រៃឈើធំទូលាយ ប្រហែលមានដល់ ៣ ភាគ ក្នុង ៤ ភាគ របស់ប្រទេស ព្រៃឈើអស់នេះជាទ្រែកស្រ័យនៅនៃសត្វព្រៃប្រទេសក្ដៅ (ដូចជាដំរី, ខ្លាជាដើម) ។ របរក្សេត្រកម្មប្រទេសក្ដៅ មានធ្វើស្ដុកស្ដម្ភនៅតំបន់ដែលមានដីទាបមានទឹកលិចឬមានផ្លូវទឹកចេញចូលបាន ដែលសំខាន់ជាងគេបំផុតគឺស្រូវ បន្ទាប់មកទៀតគឺ ម្រេច, តែ, ថ្នាំជក់, កៅស៊ូ, ឬស្សី, អំពៅ, ម្រ័ក្សណ៍, ការចាប់ត្រី (នេសាទកម្ម) យ៉ាងម៉ឺងម៉ាត់មានធ្វើពាសពេញក្នុងទន្លេសាបនឹងក្នុងដងទន្លេមេគង្គ ។ ស្រុកខ្មែរលក់មុខដំនួញចេញទៅក្រៅ គឺ ស្រូវ, ត្រីឆ្អើរ, ឈើមានដំឡៃ នាំទៅស្រុកព្រៃនគរតាមផ្លូវកប៉ាល់ដែលដើរក្នុងដងទន្លេមេគង្គ ។ ប្រជាជនជាន់ដើមបង្អស់នោះជាជាតិហិណ្ឌូ ហើយដំណាតមកជាខ្មែរ ធ្លាប់មានស៊ីវិល្យដ៏រុងរឿងមកហើយ (ក្នុងសម័យបុរាណ) ។

បណ្ដាបុរាណស្ថានខ្មែរមាន វិហារ, វត្ត, ប្រាសាទដែលជាអស្ចារ្យ-ធម៌របស់ខ្មែរអស់នោះមាននៅទិសខាងជើងទន្លេសាប (ដោយគុះគរ) ។

* * *

នៅទីបំផុតមានពាក្យពន្យល់អំពីពាក្យថា "អង្គរ" ដូច្នេះ :

អង្គរ ជាឈ្មោះក្រុងចាស់នៅខេត្តសៀមរាបក្នុងស្រុកខ្មែរ ជាទីមានបុរាណស្ថានយ៉ាងល្បីល្បាញដោយរចនាខ្មែរ មានចំនួនច្រើនជាង ៦០០ ប្រាសាទ ប្រកបដោយសិល្បៈរចនាយ៉ាងប្រសើរថ្លៃថ្លា ។ តួអង្គរគេព្យាយាមកសាងធ្វើជាទីក្រុងមួយយ៉ាងធំ បានចាប់សាងមកតាំងអំពី ព.ស. ១៣៤៣ ហើយចំរើនរុងរឿងយ៉ាងរួសរាន់ កើតជាទីក្រុងធំរបស់ប្រទេសកម្ពុជា ដែលគួរកប់ថាជាទីប្រជុំទំនៀមទម្លាប់ប្រពៃណីខ្មែរមួយ មានក្សត្រិយ៍បូករួមទាំងអស់ចំនួន ១២០ អង្គ ។ លុះមកដល់ពុទ្ធសករាជ ១៩៤៣ ក្រុងអង្គរត្រូវពួកសៀមចូលមកវាយលុកលុយខ្ទេចខ្ទីទៅ រុក្ខជាតិទាំងឡាយក៏កាន់តែដុះទ្រុបទ្រុលចំរើនឡើងបន្តិចម្ដងៗ ទាល់តែបាត់ទីក្រុងធំនេះទៅ ។ បណ្ដាប្រាសាទផ្សេងៗ នៅស្រុកសៀមរាបនេះបាក់បែកខ្ទេចខ្ទីអស់ទៅជាច្រើន តែតួប្រាសាទអង្គរវត្តនៅល្អរុងរឿងនៅឡើយ (ព.ស. ១៩៤៣) ។ ឯប្រាសាទផ្សេងៗនៅអង្គរធំហាក់ដូចជាគេសាង

បណ្ដាបុរាណស្ថានខ្មែរមាន វិហារ, វត្ត, ប្រាសាទដែលជាអច្ឆរិយ-ធម៌របស់ខ្មែរអស់នោះមាននៅទិសខាងជើងទន្លេសាប (ដោយគុះករ) ។

* * *

នៅទីបំផុតមានពាក្យពន្យល់អំពីពាក្យថា "អង្គរ" ដូច្នេះ :

អង្គរ ជាឈ្មោះក្រុងចាស់នៅខេត្តសៀមរាបក្នុងស្រុកខ្មែរ ជាទីមានបុរាណស្ថានយ៉ាងល្បីល្បាញដោយរចនាខ្មែរ មានចំនួនច្រើនជាង ៦០០ ប្រាសាទ ប្លែកៗដោយសិល្បៈរចនាយ៉ាងប្រសើរថ្លៃថ្លា ។ ក្នុងអង្គរ គេព្យាយាមកសាងធ្វើជាទីក្រុងមួយយ៉ាងធំ បានចាប់សាងមកតាំងអំពី ព.ស. ១៣៤៣ ហើយចំរើនរុងរឿងយ៉ាងរួសរាន់ កើតជាទីក្រុងធំរបស់ប្រទេសកម្ពុជា ដែលគួរពោលថាជាទីប្រជុំទំនៀមទម្លាប់ប្រពៃណីខ្មែរមួយ មានក្សត្រិយ៍បូករួមទាំងអស់ចំនួន ១៤០ អង្គ ។ លុះមកដល់ពុទ្ធសករាជ ១៩៤៣ ក្រុងអង្គរត្រូវពួកសៀមចូលមកវាយលុកលុយខ្ទេចខ្ទីទៅ រុក្ខជាតិទាំងឡាយក៏កាន់តែដុះទ្រុបទ្រុលចំរើនឡើងបន្តិចម្តងៗ ទាល់តែបាត់ទីក្រុងធំនេះទៅ ។ បណ្ដាប្រាសាទផ្សេងៗនៅស្រុកសៀមរាបនេះបាក់បែកខ្ទេចខ្ទីអស់ទៅជាច្រើន តែតួប្រាសាទអង្គរវត្តនៅល្អរុងរឿងនៅឡើយ (ព.ស. ១៩៤៣) ។ ឯប្រាសាទផ្សេងៗនៅអង្គរធំហាក់ដូចជាគេសាង

បូជាដល់សាសនាព្រាហ្មណ៍ ហើយបុរាណវត្ថុអស់នេះធន់នឹងអាកាសកាលវេលានិងព្រៃព្រឹក្សាបាន ។ សសរប្រកបដោយក្បាច់រចនាយ៉ាងវិសេស ក្បាលសសរមានក្បាច់ត្រកបឈូក នៅថ្នាក់ក្រោមមានក្បាច់ចម្លាក់រចនាយ៉ាងវិសេសសឹងមានចំនួនច្រើនលើសលន់គណនា ទាំងទំហំសោតក៏សំបើមហើយជាទីគួរពិតពិលរមិលមើល ជាគ្រឿងបង្ហាញឲ្យឃើញអារ្យធម៌និងឫទ្ធិអំណាចរបស់ប្រជាជនជាតិខ្មែរក្នុងសម័យបុរាណ ។



៤២— អំពីព្រះបច្ឆិមភិចារបស់ព្រះពុទ្ធជាម្ចាស់ ។

ភាគប្រវត្តិសាស្ត្រក្រិក

វគ្គទី ១

# សេចក្ដីផ្ដើម

ពួកក្រិកហៅខ្លួនឯងថា ហេឡែន ដែលមានឈ្មោះដូច្នេះ ព្រោះមាននិទានដំណាលថា មានបុព្វបុរសដំបូងរបស់ក្រិកនោះហៅថា ហេឡែន ជាកូនយក្ស ។ ការសិក្សាប្រវត្តិសាស្ត្ររបស់ជាតិក្រិកនេះ ធ្វើឲ្យយើងយល់ដល់គំនិតយោបល់របស់ជនជាតិអឺរ៉ុបក្នុងសម័យនេះបានច្បាស់ល្អ ព្រោះអារ្យធម៌របស់ក្រិកនោះ ជាឫសគល់របស់អារ្យធម៌អឺរ៉ុបទាំងមូល ។ ក្រិកជាជាតិដំបូងក្នុងលោកនេះ ដែលនាំយកសេចក្ដីចំរើនរបស់ទ្វីបអាស៊ី ទៅចែកផ្សាយដល់ទ្វីបអឺរ៉ុប ហើយនាំយកសេចក្ដីចំរើនរបស់អឺរ៉ុបមកផ្សាយទុកក្នុងអាស៊ី គឺថា ក្រិកជាជាតិដំបូងដែលធ្វើឲ្យអឺរ៉ុបនិងអាស៊ីមានស្ពានមេត្រីជាប់ទាក់ទងគ្នា ។

មានអ្នកប្រាជ្ញពង្សាវតារខ្លះ បានញែកចែកប្រទេសក្រិកចេញជា ២ ចំណែក គឺត្រង់កណ្ដាលផ្ទៃផែនដីធំមួយផ្នែក នៅតាមមាត់សមុទ្រមួយផ្នែក ។ ការបែងចែកដូច្នេះគ្រាន់តែសំដែងឲ្យឃើញលក្ខណៈរបស់ភូមិប្រទេសច្បាស់ មិនសូវមានប្រយោជន៍ខាងប្រវត្តិសាស្ត្រណាស់ទេ ។

ភូមិប្រទេសរបស់ក្រិក តាំងនៅលើមាត់ច្រាំងទឹកតាមកោះផ្សេង ៗ ក្នុងសមុទ្រអេស៊ីន ដែលមានឈ្មោះម្យ៉ាងទៀតថាសមុទ្រកោះ ដោយហេតុមានកោះតូចៗរដិបរដុបជាច្រើន ។ ពួកដែលនៅមាត់សមុទ្រទិសខាងកើតបំផុតនោះ មានភូមិប្រទេសខ្ពស់ៗទាបៗតាមឈូងសមុទ្រមេឌីតែ-រ៉ាណេ ។ ដែលនៅចុងឈូងសមុទ្រមានតែផែនដីមួយដុំដែលស្ទើរជាកោះ តែមានផែនដីស្តួចមួយកន្ទុងតូចប្រហែល៦គីឡូម៉ែត្រ ដែលហៅថា កូរិន្ធ (Corinthe) ខាងចុងផែនដីដែលស្ទើរជាកោះនេះមានសណ្ឋានដូចបាតដៃ ដែលបែងញែកចេញដូចចុងម្រាមដៃ ។ អាណាចក្ររបស់ពួកក្រិកទាំងអស់នោះ ទិសខាងកើតទល់នឹងសមុទ្រអេសេដែលជាព្រំប្រទល់ខណ្ឌកណ្តាលរវាងផែនក្រិកនឹងទ្វីបអាស៊ី ទិសខាងលិចទល់នឹងសមុទ្រអ៊ីអូនី-យែន (Ionienne) ដែលខណ្ឌកណ្តាលរវាងផែនក្រិកនឹងឥតាលីខាងត្បូង ហើយនៅទិសខាងត្បូងទល់នឹងសមុទ្រមេឌីតែរ៉ាណេ ឯទិសខាងជើងមិនមានព្រំប្រទល់ពិតប្រាកដ ។ បើរាប់ពីទិសខាងជើងទៅខាងត្បូងមានបណ្តោយ ៤១០ គីឡូម៉ែត្រ ឯទទឹងដីដែលធំបំផុតប្រមាណ ២១០ គីឡូ-ម៉ែត្រ រួមទីដីទាំងអស់ប្រមាណ ៥៥.៥០០ គីឡូម៉ែត្រក្រឡា ។

ភូមិប្រទេសរបស់ក្រិកមានកោះជាចំនួនច្រើន ពួកអ្នកទូកកប៉ាល់ក្នុងសមុទ្រអេសេ ឬក្នុងផ្លូវទឹកនានារបស់ក្រិកតែងមើលឃើញផែនដីជានិច្ច កោះអ៊ឺយបេ (Eubée) ដែលមើលឃើញផែនទីមានទំនងញែក

ភូមិប្រទេសរបស់ក្រិក តាំងនៅលើមាត់ច្រាំងទឹកតាមកោះផ្សេងៗ ក្នុងសមុទ្រអេស៊ីន ដែលមានឈ្មោះម្យ៉ាងទៀតថាសមុទ្រកោះ ដោយហេតុមានកោះតូចៗរដិបរដុបជាច្រើន ។ ពួកដែលនៅមាត់សមុទ្រទិសខាងកើតបំផុតនោះ មានភូមិប្រទេសខ្ពស់ៗទាបៗតាមឈូងសមុទ្រមេឌីតែ-រ៉ាណេ ។ ដែលនៅចុងឈូងសមុទ្រមានតែផែនដីមួយដុំដែលស្ទើរជាកោះ តែមានផែនដីស្តួចមួយកន្ទុយតូចប្រហែល៦គីឡូម៉ែត្រ ដែលហៅថា កូរិន្ធ (Corinthe) ខាងចុងផែនដីដែលស្ទើរជាកោះនេះមានសណ្ឋានដូចបាតដៃ ដែលបែងញែកចេញដូចចុងម្រាមដៃ ។ អាណាចក្ររបស់ពួកក្រិកទាំងអស់នោះ ទិសខាងកើតទល់នឹងសមុទ្រអេសេដែលជាព្រំប្រទល់ខណ្ឌកណ្តាលរវាងផែនក្រិកនឹងទ្វីបអាស៊ី ទិសខាងលិចទល់នឹងសមុទ្រអ៊ីអូនី-យែន (Ionienne) ដែលខណ្ឌកណ្តាលរវាងផែនក្រិកនឹងអីតាលីខាងត្បូង ហើយនៅទិសខាងត្បូងទល់នឹងសមុទ្រមេឌីតែរ៉ាណេ ឯទិសខាងជើងមិនមានព្រំប្រទល់ពិតប្រាកដ ។ បើរាប់ពីទិសខាងជើងទៅខាងត្បូងមានបណ្តោយ ៤១០ គីឡូម៉ែត្រ ឯទទឹងដីដែលធំបំផុតប្រមាណ ២១០ គីឡូ-ម៉ែត្រ រួមទីដីទាំងអស់ប្រមាណ ៥៥.៥០០ គីឡូម៉ែត្រក្រឡា ។

ភូមិប្រទេសរបស់ក្រិកមានកោះជាចំនួនច្រើន ពួកអ្នកទូកកប៉ាល់ក្នុងសមុទ្រអេសេ ឬក្នុងផ្លូវទឹកនានារបស់ក្រិកតែងមើលឃើញផែនដីជានិច្ច កោះអ៊ឺយេប (Eubée) ដែលមើលឃើញផែនទីមានទំនងញែក

ដាច់ពីផ្ទាំងដែនដីធំរបស់ក្រិកក៏ពិតមែន តែត្រង់ចន្លោះដែលដាច់ចេញពីគ្នានោះមានតំបន់ខ្លះតូចជាងដែនទន្លេសាប់ស្រុកយើងនេះក៏មាន ហេតុនេះបានជាប្រទេសក្រិកទុកជាតូចជាងស្រុកខ្មែរយើងក៏ដោយ តែមានមាត់ច្រាំងវែងដល់ទៅ ២.០០០ គីឡូម៉ែត្រ (ស្រុកខ្មែរមានមាត់សមុទ្រត្រឹម ៤០០ គីឡូម៉ែត្រប៉ុណ្ណោះ) ។ ពួកក្រិកបានញែកបំបែកចេញជាអាណាចក្រតូចៗច្រើន អាណាចក្រនិមួយៗមិនធំប៉ុន្មានទេ ប្រហែលប៉ុនខេត្តមួយរបស់យើងក៏មាន តែគេរក្សាសេរីភាពរបស់ខ្លួនដោយឡែកៗ បំបែកគ្នាគ្រប់គ្រងត្រួតត្រាដោយចំណែកៗ ដូចជាអាថែន (Athènes) ស្ប៉ាគ៍ (Sparte) ថែប៍ (Thèbes) កូរិន្ធ៍ (Corinthe) ប៉េឡូណែស (Pélonès) ។ ល ។ ហេតុនេះហើយគេយល់ថា ដែលហៅថា ក្រិក នោះគឺសំដៅយកអាណាចក្រតូចៗនៅជិតៗគ្នា មានការទាក់ទងទៅមកកាន់គ្នា តែមិនរួមគ្នាជាអាណាចក្រមួយទេ ដរាបមកដល់សម័យអាលេក្សង់ដ្រ៍មហាកដ (Alexandre) មានអំណាចរុងរឿងឡើង ទើបមានអំណាចគ្រប់គ្រងក្រិកទាំងអស់បានសំរេច ។

បានពោលពីខាងដើមរួចមកហើយថា ក្រិកហៅខ្លួនឯងថាហេឡែន ពួកហេឡែនបុរាណដែលជាឫសគល់របស់ក្រិកសុទ្ធៗនោះមាន ៤ ពួក គឺ ដារៀនស៍ អ៉ីអូលៀនស៍ អ៉ីអូនៀងស៍ (Ioniens) នឹងអាកេអែនស៍ ចុះ

ហេតុអ្វីទើបមានសាខាបែកខ្ញែកដូច្នេះ ពួកក្រិកឯងរកពន្យល់ការរបស់ខ្លួនមិនបាន ទើបបែរទៅរកវិធីដែលងាយបំផុតគឺតែងជានិទានឡើង ដែលមនុស្សសម័យបុរាណចូលចិត្តធ្វើណាស់ តាមនិទានរឿងព្រេងរបស់ក្រិកនោះមានសេចក្ដីដំណាលថា ក្នុងសម័យមួយនោះ មានយក្ស ១ ឈ្មោះប្រូមិធុស បានសាងលោកនេះឡើង (ពួកក្រិកមិនបានថាព្រះលើស្ថានសួគ៌ជាអ្នកសាងមនុស្សទេ ) ដើម្បីឲ្យមនុស្សមានជីវិតនៅក្នុងលោក ក៏ទៅលួចយកភ្លើងមកពីស៊ុវស៍ (ដែលជាព្រះមានអំណាចធំបំផុតរបស់ក្រិក) ស៊ុវស៍ទ្រង់ខ្ញាល់ខ្លាំងណាស់ ក៏ចាប់ប្រូមិធុសទៅចោះដែកគោលភ្ជាប់ទុកនៅកំពូលភ្នំ មានត្មាតមួយហើរមកចោះឆ្អឹងជំនីរស្រាវយកពោះវៀនយក្សទៅចឹកស៊ីតែរាល់ថ្ងៃ តែស៊ុវស៍មិនទាន់បាត់ខ្ញាល់ នៅត្រូវការធ្វើទោសដល់ពួកមនុស្សដែលប្រូមិធុសសាងឡើងនោះទៀតផង ទើបទ្រង់បណ្ដាលឲ្យទឹកលិចមនុស្សស្លាប់អស់ទៅ តែមានយក្សមួយជាកូនរបស់ប្រូមិធុសសាងទូកមួយឡើងរត់រួចពីឧទកភ័យទៅបាន លុះដល់ទឹករីងស្ងួតទើបយក្សនោះយកដុំថ្មបោះទំលាក់លើផែនដី កាលបោះចុះទៅមួយដុំក៏កើតជាមនុស្សម្នាក់ ៗ ក្នុងចំពួកមនុស្សដែលសាងឡើងនេះ មានមនុស្សម្នាក់ឈ្មោះហេឡែន ដែលពួកក្រិកប្រកាន់ថាជាបឋមបុរសរបស់ក្រិក ៗ ហេឡែនមានកូន២នាក់ ម្នាក់ឈ្មោះដរុ ជាបឋមបុរសរបស់ពួកដរៀនស៍ ៗ ម្នាក់ទៀតឈ្មោះ អ៊ីយូណែស ជាបឋមបុរសរបស់ពួកអ៊ីយូលៀនស៍ ហើយ

ហេតុអ្វីទើបមានសាខាបែកខ្ញែកដូច្នេះ ពួកក្រិកឯងរកពង្សាវតាររបស់ខ្លួនមិនបាន ទើបបែរទៅរកវិធីដែលងាយបំផុតគឺតែងជានិទានឡើង ដែលមនុស្សសម័យបុរាណចូលចិត្តធ្វើណាស់ តាមនិទានរឿងព្រេងរបស់ក្រិកនោះមានសេចក្ដីដំណាលថា ក្នុងសម័យមួយនោះ មានយក្ខ ១ ឈ្មោះប្រូមេធុស បានសាងលោកនេះឡើង (ពួកក្រិកមិនបានថាព្រះលើស្ថានសួគ៌ជាអ្នកសាងមនុស្សទេ) ដើម្បីឲ្យមនុស្សមានជីវិតនៅក្នុងលោក ក៏ទៅលួចយកភ្លើងមកពីស៊ីវស៍ (ដែលជាព្រះមានអំណាចធំបំផុតរបស់ក្រិក) ស៊ីវស៍ទ្រង់ខ្ញាល់ខ្លាំងណាស់ ក៏ចាប់ប្រូមេធុសទៅចោះដែកគោលភ្ជាប់ទុកនៅកំពូលភ្នំ មានត្មាតមួយហើរមកចោះថ្ពើងដំនីស្រាវយកពោះវៀនយក្ខទៅចឹកស៊ីតែពល់ថ្ងៃ តែស៊ីវស៍មិនទាន់បាត់ខ្ញាល់ នៅត្រូវការធ្វើទោសដល់ពួកមនុស្សដែលប្រូមេធុសសាងឡើងនោះទៀតផង ទើបទ្រង់បណ្ដាលឲ្យទឹកលិចមនុស្សស្លាប់អស់ទៅ តែមានយក្ខមួយជាកូនរបស់ប្រូមេធុសសាងទូកមួយឡើងរត់រួចពីឧទកភ័យទៅបាន លុះដល់ទឹករីងស្ងួតទើបយក្ខនោះយកដុំថ្មបោះទំលាក់លើផែនដី កាលបោះចុះទៅមួយដុំក៏កើតជាមនុស្សម្នាក់ ៗ ក្នុងចំពួកមនុស្សដែលសាងឡើងនេះ មានមនុស្សម្នាក់ឈ្មោះហេលែ៉ន ដែលពួកក្រិកប្រកាន់ថាជាបឋមបុរសរបស់ក្រិក ។ ហេលែ៉នមានកូន២នាក់ ម្នាក់ឈ្មោះដរុ ជាបឋមបុរសរបស់ពួកដរៀនស៍ ។ ម្នាក់ទៀតឈ្មោះអ៊ីអូលុស ជាបឋមបុរសរបស់ពួកអ៊ីអូលៀនស៍ ហើយ

មានទៅតមកទៀត ២ នាក់ ម្នាក់ឈ្មោះអែអ៊ូន ជាបុព្វបុរសរបស់ពួកអែអ៊ូទៀនស៍ ម្នាក់ទៀតឈ្មោះអាគេអ៊ូស៍ ជាបុព្វបុរសរបស់ពួកអាគេ-អែនស៍ ។ រឿងព្រេងអស់នេះយើងត្រូវការដឹងខុកសម្រាប់ពន្យល់អំពីឈ្មោះមនុស្ស ឬភូមិប្រទេសផ្សេងៗរបស់ក្រិក ហើយឈ្មោះអស់នេះចួនកាលជាឈ្មោះរបស់ភូមិប្រទេសក៏មាន ដូចជាសមុទ្រអែអ៊ូនៀន ។

ឯពួកក្រិកដែលមានគំនិតយោបល់ខ្ពង់ខ្ពស់មិនព្រមចុះចិត្តជឿនិទានបែបនេះទេ ប្រើនពាលអាងថាខ្លួនជាមនុស្សកើតនៅក្នុងតំបន់នោះឯង តែអ្នកប្រាជ្ញពង្សាវតារពិនិត្យស្រាវជ្រាវឃើញថា ពួកនេះមកពីពួកម៉េតទីងពួកប៉ែរ្ស ។ តាមធម្មតាមនុស្សពួកនេះ មានរូបឆោមល្អ មានក្លែករលើប បបូរមាត់ស្តើង ច្រមុះចុះត្រង់មកពីថ្ងាស ដែលជនជាតិឧរុបកប់អានថាជាទ្រង់ទ្រាយល្អចំណាប មានជីវិតនៅជិតសមុទ្រទីងជិតភ្នំ ហើយមានភូមិប្រទេសក៏ស្អាងជានិច្ច ជាហេតុឲ្យមនុស្សនៅតំបន់នេះមានព្យាយាមខ្នះ-ខ្នែង មានគំនិតគិតគូរស្រឡះទូលាយ ហើយមានបញ្ញាឆ្លៀវឆ្លាស ។

ជីវិតរបស់ពួកក្រិកក្នុងសម័យបុរាណនោះយើងអាចដឹងរឿងរ៉ាវបានយោងមួយពួករបស់ក្រិកហៅថាយោងហូមេរិក ដែលហៅឈ្មោះដូច្នេះព្រោះមានជំនឿថា ជនជាតិក្រិកម្នាក់ឈ្មោះ ហូម៉ែរ (Homère) ជាអ្នកតែងឡើងទាំងអស់ តែអ្នកប្រាជ្ញអក្សរសាស្ត្រសម័យនេះសន្និដ្ឋានថា

បទឃោងអស់នេះមានអ្នកតែងច្រើនគ្នា តែហូមែរជាអ្នកតែងច្រើនជាងគេឯទៀត ។ បទឃោងអស់នេះមានពោលពីរឿងចម្បាំងជាដើម សំដែងឲ្យឃើញជីវិតនិងទំនៀមប្រពៃណីរបស់ក្រិកក្នុងសម័យបុរាណ ។

ហេតុប្រព្រឹត្តទៅនៃប្រជាជនជាតិក្រិកក្នុងសម័យបុរាណ ជាបុគ្គលដែលធ្វើការងារផ្សេងៗបានគ្រប់យ៉ាងសូម្បីស្តេចសោយរាជ្យក៏គោងតែធ្វើការដូចបណ្តាកស្រ្ត ៗ ពួកមេទ័ពដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញទៅចម្បាំងមានជ័យជំនះមកហើយ លុះផុតចម្បាំងក៏គោងតែធ្វើការងារចិញ្ចឹមជីវិតដូចមនុស្សធម្មតា មានពាក្យឃោងមួយអទ្វើថា ព្រះចៅផែនដីមួយអង្គ វេលាមានការប្រជុំអមាត្យមន្ត្រី ព្រះរាជជននីទ្រង់ប្រាថ្នានឹងចូលប្រជុំផង ព្រះចៅផែនដីអង្គនោះទ្រង់មានព្រះបន្ទូលនឹងព្រះរាជជននីថា "អញ្ជើញស្តេចម៉ែត្រឡប់ទៅទីប្រថាប់ ដើម្បីធ្វើការត្បាញសំពត់និងការងារក្នុងផ្ទះផ្សេងៗ ចំណែកខាងការស្រុកទេសនោះជាមុខក្រសួងរបស់មនុស្សប្រុសទេតើ" ដូច្នេះ ។ ក្រៅពីនេះបទឃោងអស់នេះសំដែងឲ្យឃើញថា ពួកក្រិកប្រកាន់ការបដិសណ្ឋារៈជាកិច្ចដ៏សំខាន់មួយ មនុស្សប្លែកចូលមកដល់ផ្ទះ ម្ចាស់ផ្ទះគោងចាត់ការ៉ាប់រងដូចជាទូតដំណាងរបស់ព្រះជាម្ចាស់ ។

ពួកក្រិកជាពួកគោរពរាប់អានព្រះដូចជាមនុស្សបុរាណជាតិឯទៀតៗដែរ ព្រះរបស់ក្រិកមានចំនួនច្រើនដូចជាអេស៊ីបដែរ តែបើពោលតាម

បទឃ្លោងអស់នេះមានអ្នកតែងច្រើនគ្នា តែហូម៉ែរជាអ្នកតែងច្រើនជាងគេឯទៀត ។ បទឃ្លោងអស់នេះមានពោលពីរឿងចម្បាំងជាដើម សំដែងឲ្យឃើញជីវិតនិងទំនៀមប្រវេណីរបស់ក្រិកក្នុងសម័យបុរាណ ។

ហេតុប្រព្រឹត្តទៅនៃប្រជាជនជាតិក្រិកក្នុងសម័យបុរាណ ជាបុគ្គលដែលធ្វើការងារផ្សេងៗបានគ្រប់យ៉ាងសម្បីស្តេចសោយរាជ្យក៏គោងតែធ្វើការដូចបណ្តាកស្ត្រ ។ ពួកមេទ័ពដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញទៅច្បាំងមានជ័យជំនះមកហើយ លុះផុតចម្បាំងក៏គោងតែធ្វើការងារចិញ្ចឹមជីវិតដូចមនុស្សធម្មតា មានពាក្យឃ្លោងមួយអទ្វើថា ព្រះចៅផែនដីមួយអង្គ វេលាមានការប្រជុំអមាត្យមន្ត្រី ព្រះរាជជននីទ្រង់ប្រាថ្នានឹងចូលប្រជុំផង ព្រះចៅផែនដីអង្គនោះទ្រង់មានព្រះបន្ទូលទៅព្រះរាជជននីថា "អញ្ជើញស្តេចម៉ែត្រឡប់ទៅទីប្រថាប់ ដើម្បីធ្វើការត្បាញសំពត់និងការងារក្នុងផ្ទះផ្សេងៗ ចំណែកខាងការស្រុកទេសនោះជាមុខក្រសួងរបស់មនុស្សប្រុសទេតើ" ដូច្នេះ ។ ក្រៅពីនេះបទឃ្លោងអស់នេះសំដែងឲ្យឃើញថា ពួកក្រិកប្រកាន់ការបដិសណ្ឋារៈជាកិច្ចដ៏សំខាន់មួយ មនុស្សប្លែកចូលមកដល់ផ្ទះ ម្ចាស់ផ្ទះគោងចាត់ការរ៉ាប់រងដូចជាទូតដំណាងរបស់ព្រះជាម្ចាស់ ។

ពួកក្រិកជាពួកគោរពរាប់អានព្រះដូចជាមនុស្សបុរាណជាតិឯទៀតៗដែរ ព្រះរបស់ក្រិកមានចំនួនច្រើនដូចជាអេស៊ីបក៏ដែរ តែបើពោលតាម

ផ្សាយសាសនា ពួកក្រិកខុសនឹងជនបុរាណក្នុងសម័យនោះខ្លះ គោលគឺសីល-ធម៌ឬធម្មក្រឹត្យរបស់មនុស្សមិនមែនព្រះទ្រង់បញ្ញត្តឡើងទេ ពួកលោកសង្ឃមិនមាននាទីបង្ហាត់បង្រៀនសីលធម៌ដូចយ៉ាងសាសនាឯទៀតៗទេ មុខក្រសួងនេះជានាទីរបស់ពួកអ្នកប្រាជ្ញបរមត្ថវិជ្ជា (Philosophes) និងពួកអ្នកប្រព័ន្ធរឿង ។ ហេតុនេះ គោលរបស់សាសនាក្រិកទើបមានទំនងប្លែកពីសាសនាដទៃៗក្នុងផែនដីបំណែកនោះ គឺពួកព្រះជាម្ចាស់អស់នោះបើធ្វើអ្វីខុសក៏គង់តែទទួលទោសផងដែរ អ្នកធ្វើខុសគង់តែទទួលទោសដោយខ្លួនឯង នេះចាត់ជាជំហានមួយនៃគំនិតរបស់មនុស្សដែលមិនព្រមជឿព្រះជាម្ចាស់ហួសពេក ដែលតែងប្រកាន់ថាព្រះទ្រង់ធ្វើអ្វីគ្រប់យ៉ាងមិនដែលមានខុស ។

ក្រៅពីនេះ ប្រជាជនជាតិក្រិកមានសេចក្ដីគោរពរាប់អានបុព្វបុរសរបស់ខ្លួនដូចជាព្រះលើស្ថានសួគ៌ដែរ ដោយយល់ថាបុព្វបុរសរបស់ខ្លួនកាលបើស្លាប់ទៅហើយ វិញ្ញាណរបស់លោកនៅតែមកនៅរួមជាមួយនឹងកូនចៅ ចាំការពាររក្សានឹងកេរ្តិ៍យសសក្ដិឲ្យកូនចៅនៅក្រោយៗតមក ហេតុនេះបានជាខំព្យាយាមធ្វើដំរូវចិត្តរបស់បុព្វបុរស ដូចជានាំអាហារភោជនទៅសែនដល់ផ្នូរជាទីកប់ខ្មោច ហើយក្នុងគ្រួសារនីមួយៗរមែងមានទីសម្រាប់ធ្វើសក្ការបូជាដល់បុព្វបុរសរបស់ខ្លួនជានិច្ច ។

ព្រះរបស់ពួកក្រិកមានច្រើន តែមានអង្គធំៗដែលគួរស្គាល់ព្រោះ សម្រាប់ជាគ្រឿងប្រដាប់សតិបញ្ញារបស់យើង:

១ – ស៊ីស (Zeus: ព្រះព្រហស្បតិ៍) ជាព្រះអង្គធំបំផុត ។

២ – ហេរ៉ា (Héra: ស្ថានសួគ៌) ជាព្រះប៉ែកខាងអាពាហ៍ពិពាហ៍ ។

៣ – អាធេណេ (Athéné ព្រះផ្គកបន្ទោរ) ជាព្រះនៃសតិបញ្ញា ។

៤ – អារតេមីស (Artémis: ព្រះចន្ទ) ជាព្រះនៃសេចក្ដីបរិសុទ្ធ ។

៥ – អាប្រូឌីត (Aphrodite: ព្រះសុក្រ) ជាព្រះនៃលំអ ។

៦ – ដេមេតែរ (Déméter: នាងធរណី) ជាព្រះនៃផែនដី ។

៧ – អាប៉ុល្ល៉ុង (Apollon: ព្រះអាទិត្យ) ជាព្រះនៃការបទានទឹងអក្សរ-សាស្ត្រ ។

៨ – ហេរ៉ម៉ែស (Hermès ព្រះពុធ) ជាព្រះនៃភ្ញៀវនឹងជាព្រះនៃសំដីនិយាយផង ។

៩ – អារែស (Arès: ព្រះអង្គារ) ជាព្រះនៃកាំរទេះនឹងជាព្រះនៃសង្គ្រាមផង ។

១០ – ហេហ្វេស្ទុស (Héphaistos: ព្រះភ្លើងនៅក្រោមដី) ជាព្រះនៃសិប្បកម្ម ។

១១ – ប៉ូសីដុង (Poseidon: ព្រះសមុទ្រ) ជាព្រះនៃកំហឹង ។

១២ – ហេស្ទិយ៉ា (Hestia: ព្រះភូមិ) ជាព្រះនៃមេផ្ទះសំបែង ។

ព្រះរបស់ពួកក្រិកមានច្រើន តែមានអង្គធំៗដែលគួរស្គាល់នោះ សម្រាប់ជាគ្រឿងប្រដាប់សតិបញ្ញារបស់យើង:

១ – ស៊ឺស (Zeus: ព្រះព្រហស្បតិ៍) ជាព្រះអង្គធំបំផុត ។

២ – ហេរ៉ា (Héra: ស្ថានសួគ៌) ជាព្រះប៉ែកខាងអាពាហ៍ពិពាហ៍ ។

៣ – អាថេណេ (Athéné ព្រះផ្គុកបន្ទោរ) ជាព្រះនៃសតិបញ្ញា ។

៤ – អារតេមីស (Artémis: ព្រះចន្ទ) ជាព្រះនៃសេចក្តីបរិសុទ្ធ ។

៥ – អាប្រូឌីត (Aphrodite: ព្រះសុក្រ) ជាព្រះនៃបេ៉ម ។

៦ – ដេមេតែរ (Déméter: នាងធរណី) ជាព្រះនៃផែនដី ។

៧ – អាប៉ុល្លុង (Apollon: ព្រះអាទិត្យ) ជាព្រះនៃការបេទានអក្សរ-សាស្ត្រ ។

៨ – ហែរមែស (Hermès ព្រះពុធ) ជាព្រះនៃភ្ញៀវផងជាព្រះនៃសំដីនិយាយផង ។

៩ – អារែស (Arès: ព្រះអង្គារ) ជាព្រះនៃកាំរទេះផងជាព្រះនៃសង្គ្រាមផង ។

១០ – ហេហ្វេស្តុស (Héphaistos: ព្រះភ្លើងនៅក្រោមដី) ជាព្រះនៃសិប្បកម្ម ។

១១ – ប៉ូស៊ីដុង (Poseidon: ព្រះសមុទ្រ) ជាព្រះនៃកំហឹង ។

១២ – ហេស្ទីយ៉ា (Hestia: ព្រះភូមិ) ជាព្រះនៃមេផ្ទះសំបែង ។

យើងមើលឃើញថា ព្រះផ្សេងៗអស់នេះពួកក្រិករើសប្រមូលយកមកពីធម្មជាតដែលនៅក្នុងលោក ដូចជាភ្លៀងធ្លាក់ ផ្គរលាន់ កំដៅនៅក្រោមដី សមុទ្រមានរលក របស់អស់នេះកើតឡើងដោយអំណាចព្រះនីមួយៗ ការធ្វើឲ្យព្រះសព្វព្រះទ័យ ក៏មានវិធីយកសត្វដូចជាគោទៅសំឡាប់សែនបូជាចំពោះព្រះភក្ត្រទេវរូប មានលោកសង្ឃជាអ្នកធ្វើពិធីបូជា តែលោកសង្ឃរបស់ក្រិកមិនបានចាត់ជាវណ្ណៈមួយដោយឡែកដូចអេស៊ីប្ដឬពួកព្រាហ្មណ៍ក្នុងឥណ្ឌានោះទេ លោកសង្ឃគ្រាន់តែមាននាទីធ្វើពិធីបួងសួងព្រះជាម្ចាស់ប៉ុណ្ណោះ មិនបានប្រដៅសីលធម៌ឬធម្មចរិយាឯណានីមួយដល់ប្រជាជនឡើយ ។

(នៅមានត)



៤៣– អំពីការបរិនិព្វាន ។

អនាមយកថា

១. ស.

អ្នកប្រែនិងរៀបរៀង

(នៅមានត)

អនាមយគាថា

ព្រោះខ្សែសរសៃសម្រាប់ឲ្យដឹងសម្ផស្សផ្សេងៗ នោះដាច់ខាតចេញពីគ្នា ។

ក) ខួរក្បាលនៅចំណែកខាងៗ និងខាងចុងរណ្ដៅប្រឡាយសង្កត់ខាងឆ្វេង សម្រាប់ធ្វើឲ្យចេះនិយាយ-សរសេរ-មើល កាលបើអវយវៈចំណែកនេះខូចខាតអន្តរាយទៅ ទើបធ្វើឲ្យនិយាយមិនកើត សរសេរមិនកើត ឯមនុស្សដែលគនិយាយមិនរួចនោះ គេច្រើននិយាយថាមនុស្សមានកន្ទើតវិពាក តែសេចក្ដីពិតមិនមានទោសកើតមកពីកន្ទើតវែងឬខ្លីឡើយ ។

ខ) ឯខួរក្បាលតូចៗ នៅខាងក្រោមនិងខាងក្រោយខួរក្បាលធំនោះ សម្រាប់ធ្វើឲ្យរាងកាយតាំងនៅនឹងបានមិនទ្រេតទ្រោត នៅចំណែកខាងស្ដាំឃុំគ្រងរាងកាយចំណែកខាងស្ដាំ ចំណែកខាងឆ្វេងឃុំគ្រងរាងកាយខាងឆ្វេង មិនប្ដូរមុខក្រសួងគ្នាដូចជាខួរក្បាលធំទេ ។ (ប្រសិនបើទារកដែលទើបសម្រាលថ្មីៗ មានខួរក្បាលចំរើនប៉ុននឹងក្មេងធំតែម្ដងមុខតែនឹងធ្វើឲ្យទារកដែលទើបសម្រាលនោះចេះឈរ- អង្គុយ- ដើរបានមួយរំពេចដូចជាសត្វតិរច្ឆានចំពួកខ្លះមិនខាន តែនឹងនាំឲ្យលំបាកដល់អ្នកអភិបាលក្មេង ព្រោះក្មេងនឹងដើរធ្លាក់ពីលើផ្ទះមិនខាន ព្រោះក្មេងមិនទាន់មានសតិសម្បជញ្ញៈ ។ ហេតុនេះ ការដែលក្មេងក្របានចេះឈរដើរ អង្គុយខ្លួនឯងមានទំនងដូចសព្វថ្ងៃនេះ ជាការគាប់ប្រសើរណាស់) ។

## (២) ខួរឆ្អឹងខ្នង

ខួរឆ្អឹងខ្នងនេះ មានលក្ខណៈដូចជាខួរក្បាលដែរ មានបណ្ដោយប្រមាណ ១៨ ធ្នាប់ ជាប់ជាមួយនឹងខួរក្បាល រលាយជាសាច់មួយចុះមកតាមបន្ទោះឆ្អឹងខ្នងផុតត្រឹមឆ្អឹងបង្កេះទី១ ដើម្បីទទួលសេចក្ដីរាយការដែលបញ្ជូនមកតាមសរសៃប្រសាទផ្សេងៗ ក្នុងរាងកាយបញ្ជូនមកដល់ខួរក្បាល ។ ឯចំណែកខាងក្រោមនៃខួរឆ្អឹងខ្នង ក៏ទទួលដឹងចំពោះរាងកាយជាចំណែកខាងក្រោមមានជើងជាដើម ហើយឡើងមកជាលំដាប់រហូតដល់ចំណែកលើខ្លួននឹងដើមដៃ សន្មតថាកើតមានគ្រោះថ្នាក់ដល់ខួរឆ្អឹងខ្នងត្រង់កណ្ដាលខ្នង អវយវៈត្រង់ចំណែកនោះប្រើការមិនបាន សេចក្ដីរាយការផ្សេងៗដែលត្រូវបញ្ជូនមកតាមប្រសាទនោះ តោងតែធ្វើដំណើរមកតាមខួរឆ្អឹងខ្នងទាំងអស់ ទើបខួរឆ្អឹងខ្នងនាំសេចក្ដីរាយការអស់នោះទៅដល់ខួរក្បាលមួយជាន់ទៀតជាលំដាប់លំដោយ ដើម្បីមិនឲ្យប្រសាទតូចៗ នាំសេចក្ដីរាយការដើររំលងថ្នាក់ត្រង់សំដៅទៅខួរក្បាលតែម្ដងៗ រឿងនេះមានទំនងដូចក្រសួងរាជការនឹងមន្ទីរធ្វើការធំៗ ដែលចាត់របៀបតាមថ្នាក់តូច ថ្នាក់ធំ មិនឲ្យធ្វើការរំលងថ្នាក់ដែលជាហេតុធ្វើឲ្យកិច្ចការផ្សេងៗកើតកើរជាកោលាហលឡើង ។

## (២) ខួរឆ្អឹងខ្នង

ខួរឆ្អឹងខ្នងនេះ មានលក្ខណៈដូចជាខួរក្បាលដែរ មានបណ្ដោយប្រមាណ ១៥ ធ្នាប់ ជាប់ជាមួយនឹងខួរក្បាល រលាយជាសាច់មួយចុះមកតាមបន្ទោះឆ្អឹងខ្នងផុតត្រឹមឆ្អឹងបង្កេះទី១ ដើម្បីទទួលសេចក្ដីកយការដែលបញ្ជូនមកតាមសរសៃប្រសាទផ្សេង ៗ ក្នុងរាងកាយបញ្ជូនមកដល់ខួរក្បាល ។ ឯចំណែកខាងក្រោមនៃខួរឆ្អឹងខ្នង ក៏ទទួលដឹងត្ងំពោះរាងកាយជាចំណែកខាងក្រោមមានជើងជាដើម ហើយឡើងមកជាលំដាប់រហូតដល់ចំណែកលើខ្លួននឹងដើមដៃ សន្មតថាកើតមានគ្រោះថ្នាក់ដល់ខួរឆ្អឹងខ្នងត្រង់កណ្ដាលខ្នង អវយវៈត្រង់ចំណែកនោះប្រើការមិនបាន សេចក្ដីកយការផ្សេងៗដែលត្រូវបញ្ជូនមកតាមប្រសាទនោះ គោងតែធ្វើដំណើរមកតាមខួរឆ្អឹងខ្នងទាំងអស់ ទើបខួរឆ្អឹងខ្នងនាំសេចក្ដីកយការអស់នោះទៅដល់ខួរក្បាលមួយជាន់ទៀតជាលំដាប់លំដោយ ដើម្បីមិនឲ្យប្រសាទតូចៗនាំសេចក្ដីកយការដើររំលងថ្នាក់ត្រង់សំដៅទៅខួរក្បាលតែម្ដងទេ ។ រឿងនេះមានទំនងដូចក្រសួងរាជការនឹងមន្ទីរធ្វើការធំៗ ដែលចាត់របៀបតាមថ្នាក់តូច ថ្នាក់ធំ មិនឲ្យធ្វើការរំលងថ្នាក់ដែលជាហេតុធ្វើឲ្យកិច្ចការផ្សេង ៗ កើតកើរជាកោលាហលឡើង ។

## (៣) សរសៃប្រសាទ

មានលក្ខណៈមានព័ណ៌សម្បុរសល្ហលឿង ជាសរសៃតូចៗឆ្មារដូចជាសរសៃអម្បោះរួមគ្នាជាបាច់ៗ ហើយក្នុងបាច់សរសៃអស់នោះមានសរសៃប្រសាទសម្រាប់ធ្វើឲ្យដឹងខ្លួនទីងសរសៃដែលធ្វើឲ្យដុំសាច់រួមផ្ដុំគ្នាបានញែកចេញជាសរសៃល្អិតៗមករួមប្រជុំក្នុងដុំសាច់ទីងសើស្បែកគ្រប់អះវ័វ សរសៃប្រសាទអស់នេះហើយដែលចេញមកអំពីខួរឆ្អឹងខ្នង មាន ៣១ គូ សម្រាប់រក្សារាងកាយ មាន ១២ គូទៀតសម្រាប់ឃុំរក្សាទូមុខទីងក្បាលៗ ការដែលមានសរសៃប្រសាទចំពួកខួរទទួលស្មើសេចក្ដីពយការ សំដៅត្រង់ទៅដល់ខួរក្បាលតែម្ដងមិនបាច់បញ្ជូនមកតាមខួរឆ្អឹងខ្នងនោះ ប្រយោជន៍ទីងឲ្យកិច្ចការប្រព្រឹត្តទៅបានស្រួលរហ័សរួសរាន់ មានទំនងដូចជាមេភាហានខ្ទះក្នុងកងទ័ព ឲ្យមានអំណាចស្មើការផ្ទាល់លោកមេទ័ពតែម្ដងបាន មិនបាច់ស្មើការតាមលំដាប់ថ្នាក់លំដាប់ថ្នាក់ដូចមេភាហានឯទៀតៗ ។

## វិធីស្ដីការក្នុងរាងកាយ

១) សន្មតិថា ម្រាមដើងរបស់យើងប៉ះកំដៅភ្លើង នេះធ្វើឲ្យចុងសរសៃប្រសាទដឹងថាក្ដៅ ហើយបញ្ជូនពយការទៅតាមសរសៃដែលជាប់ទាក់ទងគ្នាទីងខួរឆ្អឹងខ្នង ទើបខួរឆ្អឹងខ្នងនាំបញ្ជូនដំណឹងនេះទៅដល់

ខួរខាងលើ ចំណែកនេះក៏បកបញ្ជូនទៅដល់ខួរជាចំណែកនៅខាងមុខ ដែលមាននាទីទទួលទុកនូវការចាំគ្រប់ចំពូក ក៏នឹកឃើញចាំបានថា ធម្ម-ជាតិភ្លើងក្តៅ បើមិនដកឬទាញយកជើងចេញទេ មុខជាម្រាមជើងនឹងឆេះភ្លើងមិនខាន ទើបបង្គាប់ទៅដល់សរសៃប្រសាទដែលនៅប្រចាំជើងឲ្យដកជើងចេញពីភ្លើងយ៉ាងប្រញាប់ ប៉ុន្តែការស្តីការនឹងបង្គាប់ការ ទទួលប្រតិបត្តិការនោះរហ័សរួសរាន់ណាស់ ដូចជាផ្លេកបន្ទោរ ទើបធ្វើឲ្យយើងមិនដឹងខ្លួនហើយស្តីការយ៉ាងដាច់ស្រេចមិនចាំបាច់ពារង់ទេ ។ ប្រសិនបើអាល័យការរង់ពិគ្រោះប្រឹក្សាថា ត្រូវផ្លុំភ្លើងឲ្យរលត់ទៅ ឬនឹងប្រើដៃចាប់ភ្លើងចេញដូច្នោះ មុខជាម្រាមជើងយើងនឹងរលាកភ្លើងអស់មិនខាន ។

២) សន្មតថា មូសពាំមកទំខាំនូវមុខយើង ដំបៅដែលកើតពីមូសខាំនោះនឹងរត់សួរទៅតាមសរសៃប្រសាទប្រាប់ទៅនាទីផ្សេងៗដូចពោលមកហើយ តែសេចក្តីថ្មីករបស់យើងបង្គាប់ឲ្យយកដៃទះមូសនោះ ដែលជាវិធីស្រួលជាងញាក់មុខឬអង្រួនក្បាលដេញមូស ទើបស្តីបង្គាប់ទៅដៃឲ្យទះមូសដូច្នេះជាដើម ។

៣) សន្មតថា មានមនុស្សមកជេរយើងនៅចំពោះមុខ ពាក្យជេរនោះស្ទុះទៅចូលត្រចៀកហើយជូនដំណឹងទៅដល់ខួរដែរ តែមុននឹងបង្គាប់ឲ្យធ្វើតបតទៅវិញនោះលំបាកបន្តិច តោងប្រើសេចក្តីត្រិះរិះបន្តិចថាត្រូវធ្វើដូចម្តេចទើបស្រួល មានវិធីដែលត្រូវធ្វើតបតទៅវិញច្រើនយ៉ាង:

ខួរខាងលើ ចំណែកនេះក៏បកបញ្ជូនទៅដល់ខួរជាចំណែកនៅខាងមុខ ដែលមាននាទីទទួលទុកនូវការចាំត្រង់ចំណុច ក៏នឹកឃើញចាំបានថា ធម្ម-ជាតិភ្លើងក្តៅ បើមិនដកប្រញាប់យកដៃចេញទេ មុខជាម្រាមដៃនឹងឆេះភ្លើងមិនខាន ទើបបង្គាប់ទៅដល់សរសៃប្រសាទដែលនៅប្រចាំដៃឲ្យដកដៃចេញពីភ្លើងយ៉ាងប្រញាប់ ប៉ុន្តែការស្តីការនឹងបង្គាប់ការ ទទួលប្រតិបត្តិការនោះរហ័សរួសរាន់ណាស់ ដូចជាផ្លេកបន្ទោរ ទើបធ្វើឲ្យយើងមិនដឹងខ្លួនហើយស្តីការយ៉ាងដាច់ស្រេចមិនចាំបាច់ការង់ទេ ។ ប្រសិនបើអាល័យការង់ពិគ្រោះប្រឹក្សាថា ត្រូវផ្លុំភ្លើងឲ្យរលត់ទៅ ឬនឹងប្រើដៃចាប់ភ្លើងចេញដូច្នោះ មុខជាម្រាមដៃយើងនឹងរលាកភ្លើងអស់មិនខាន ។

២) សន្មតិថា មូសវាមកទំខាំនូវមុខយើង ដម្បីដែលកើតពីមូសខាំនោះនឹងរត់សួរទៅតាមសរសៃប្រសាទប្រាប់ទៅនាទីផ្សេងៗដូចពោលមកហើយ តែសេចក្តីថ្មីករបស់យើងបង្គាប់ឲ្យយកដៃទះមូសនោះ ដែលជាវិធីស្រួលជាងញាក់មុខឬអង្រួនក្បាលដេញមូស ទើបស្តីបង្គាប់ទៅដៃឲ្យទះមូសដូច្នេះជាដើម ។

៣) សន្មតិថា មានមនុស្សមកជេរយើងនៅចំពោះមុខ ពាក្យជេរនោះស្ទុះទៅចូលត្រចៀកហើយជូនដំណឹងទៅដល់ខួរដែរ តែមុននឹងបង្គាប់ឲ្យធ្វើតបតទៅវិញនោះលំបាកបន្តិច តោងប្រើសេចក្តីត្រិះរិះបន្តិចថាត្រូវធ្វើដូចម្តេចទើបស្រួល មានវិធីដែលត្រូវធ្វើតបតទៅវិញច្រើនយ៉ាង:

ក) ប្រសិនបើអ្នកដែលត្រូវគេជេរនោះជាមនុស្សចាស់ទុំ មានគំនិតគិតគូរច្រើន ដឹងខុសដឹងត្រូវ ក៏ធ្វើជាមិនដឹងមិនឮក៏មាន ឬចាត់ការតាមដែលឃើញថាជាសេចក្តីគាប់គួរ ដូចជាបណ្តេញឲ្យមនុស្សជេរដើរចេញ ឬប្តឹងប៉ូលិសឲ្យចាប់ធ្វើទោសតាមច្បាប់ក៏មាន ។

ខ) បើអ្នកដែលត្រូវជេរមានឋានៈស្មើគ្នានឹងអ្នកជេរ ខួរក្បាលបង្គាប់ឲ្យជេរតបទៅវិញ កើតជាវិវាទទាស់ទែងគ្នាមិនដាច់ស្រេចទាល់តែប៉ូលិសចាប់ទាំងពីរនាក់នាំទៅផ្ទះបកក៏មាន ។

គ) បើអ្នកដែលត្រូវជេរជាមនុស្សទោសៈខ្លាំង អត់សង្កត់ចិត្តពុំបាន ខួរក្បាលក៏ប្រើដៃជើងឲ្យទាត់ដាក់អ្នកជេរមួយរំពេចទៅក៏មាន ។

តាមឧទាហរណ៍ដែលពោលមកនេះ ដើម្បីសំដែងឲ្យឃើញថា កាយរបស់យើងនេះមានវិធីស្តីការជារបៀបរៀបរយល្អណាស់ ទាំងរហ័សទាំងដាច់ស្រេច ប៉ុន្តែកិច្ចការដែលចាត់ចែងធ្វើទៅនោះ នឹងមានសេចក្តីចំរើនឬមិនចំរើន ស្រេចតែសេចក្តីត្រិះរិះប៉ិនប្រសប់ឈ្លាសវៃនៃខួរក្បាល មានទំនងដូចចាងហ្វាងសាលា ឬអធិបតីនៃក្រសួងនិមួយៗដូច្នោះដែរ ។

មួយវិញទៀត គ្រឿងសម្ផស្សផ្សេងៗ តោងប្រព្រឹត្តទៅមិនស្រួលជាដរាប បើមានខូចខាតត្រង់កន្លែងណាមួយដូចជាខួរឆ្អឹងខ្នងពិការ កងកាយដែលនៅក្រោមខួរឆ្អឹងខ្នងក៏ប្រើការមិនកើត ។ រឿងនេះមានទំនងដូចខ្សែភ្លើងអគ្គិសនី បើខ្សែនៅក្រៅផ្ទះដាច់ ភ្លើងក្នុងផ្ទះក៏រលត់អស់មិនខាន ។

## បទទី ៣

# ហេតុដែលនាំឲ្យកើតរោគ

អ្នកប្រាជ្ញខាងវិជ្ជាពេទ្យសាស្ត្របានព្យាយាមស្រាវជ្រាវរកដើមហេតុដែលនាំឲ្យកើតរោគមកជាច្រើនជំនាន់អាយុមនុស្សហើយ ក្នុងទីបំផុតបានសេចក្ដីថា មូលហេតុដែលនាំឲ្យកើតរោគមាន ៣ យ៉ាងគឺ

១) រាងកាយយើងមានកំឡាំងខ្សោយ

២) មានមេជម្ងឺឬមីក្រុបមកប៉ះពាល់ដល់រាងកាយ

៣) មានគ្រឿងចម្លងមេរោគ ។

ហេតុទាំង ៣ ប្រការ ប្រមូលរួមគ្នា ទើបធ្វើឲ្យរាងកាយកើតរោគឡើង បើមានតែយ៉ាងណាមួយ មិនគ្រប់ព្រមគ្នាទាំង ៣ ប្រការទេ ក៏មិនកើតរោគដែរ ហេតុនេះ ទើបមានវិធីការពាររោគដូច្នេះគឺ

១) ត្រូវប្រយ័ត្នកុំឲ្យរាងកាយទន់ខ្សោយថយកំឡាំង

២) ត្រូវរៀនឲ្យស្គាល់មីក្រុបឬមេជម្ងឺផ្សេង ៗ

៣) ត្រូវរៀនឲ្យដឹងថា មានអ្វីខ្លះជាគ្រឿងចម្លងមេរោគ ។

## ១– រាងកាយមានកំឡាំងខ្សោយ

អាកាស, ការសំអាតនិងគ្រឿងអាហារ ភោជនទាំង ៣ មុខនេះអាចធ្វើឲ្យរាងកាយ មានកំឡាំងខ្លាំងពូកែឬធ្វើឲ្យទន់ខ្សោយកំឡាំងបានដូចពោលតទៅនេះ:

## បទទី ៣

# ហេតុដែលនាំឲ្យកើតរោគ

អ្នកប្រាជ្ញខាងវិជ្ជាពេទ្យសាស្ត្របានព្យាយាមស្រាវជ្រាវរកដើមហេតុដែលនាំឲ្យកើតរោគមកដាក់ច្រើនដំណអាយុមនុស្សហើយ ក្នុងទីបំផុតបានសេចក្ដីថា មូលហេតុដែលនាំឲ្យកើតរោគមាន ៣ យ៉ាងគឺ

១) រាងកាយយើងមានកំឡាំងខ្សោយ

២) មានមេជម្ងឺឬមីក្រុបមកប៉ះពាល់ដល់រាងកាយ

៣) មានគ្រឿងចម្លងមេរោគ ។

ហេតុទាំង ៣ ប្រការប្រមូលរួមគ្នាទៅទើបធ្វើឲ្យរាងកាយកើតរោគឡើង បើមានតែយ៉ាងណាមួយមិនគ្រប់ព្រមគ្នាទាំង ៣ ប្រការទេ ក៏មិនកើតរោគដែរ ហេតុនេះ ទើបមានវិធីការពាររោគដូច្នេះគឺ

១) ត្រូវប្រយ័ត្នកុំឲ្យរាងកាយទន់ខ្សោយថយកំឡាំង

២) ត្រូវរៀនឲ្យស្គាល់មីក្រុបឬមេជម្ងឺផ្សេងៗ

៣) ត្រូវរៀនឲ្យដឹងថា មានអ្វីខ្លះជាគ្រឿងចម្លងមេរោគ ។

## ១– រាងកាយមានកំឡាំងខ្សោយ

អាកាស, ការសំអាតនិងគ្រឿងអាហារភោជនទាំង ៣ មុខនេះអាចធ្វើឲ្យរាងកាយមានកំឡាំងខ្លាំងពូកែឬធ្វើឲ្យទន់ខ្សោយកំឡាំងបានដូចពោលតទៅនេះ:

# អាកាស

អាកាសឬខ្យល់ជារបស់សម្រាប់ប្រើក្នុងការដកដង្ហើមរបស់យើង ជីវិតរបស់យើងដែលរស់នៅបានសព្វថ្ងៃនេះក៏ព្រោះមានអាកាស ប្រសិនបើមិនមានខ្យល់អាកាសសម្រាប់ដកដង្ហើមទេ មុខជាយើងនឹងស្លាប់មួយរំពេចមិនខាន ។ ប្រសិនបើយកដបកែវមួយមកចាប់កណ្ដុរដាក់ក្នុងដបនោះហើយបិទមាត់ដបឲ្យជិតកុំឲ្យខ្យល់អាកាសចេញចូលបាន កណ្ដុរនោះមុខជានឹងស្លាប់ក្នុង ១០ មីនុតមិនខាន ។ នេះចង្អុលឲ្យឃើញថាកណ្ដុរនោះត្រូវការដកដង្ហើមចេញចូលដូចមនុស្សយើងដែរ ឬប្រសិនបើល្បងយកដៃខ្ទប់បិទរន្ធច្រមុះមាត់របស់យើងមិនឲ្យខ្យល់ដកដង្ហើមចេញចូលទេ មុខជាយើងអត់ធន់ទ្រាំពុំបាន បើមិនដកដៃចេញនឹងដាច់ខ្យល់ស្លាប់មិនខាន នេះជារបស់សំខាន់មួយរបស់អាកាសឬខ្យល់ ។

ក្នុងបន្ទប់ដែលយើងនៅនោះបើមានខ្នាតតូចហើយមានចំនួនមនុស្សនៅច្រើន ខ្លួនយើងមែងដឹងខ្លួនច្បាស់ថា រាដកដង្ហើមមិនស្រួលហើយមានអាការឈឺក្បាល ដូច្នេះតើមកពីហេតុអ្វី?-ព្រោះអាកាសមិនមានចំនួនល្មមគ្រប់គ្រាន់ បើនិយាយតាមច្បាប់សុខវិទ្យា នឹងឃើញថា មនុស្សគ្រប់រូបត្រូវការអាកាសសម្រាប់ដកដង្ហើម ដោយហោចទៅបន្ទប់នោះគោងមានបណ្ដោយ ៣ ម៉ែត្រ ទទឹង ៣ ម៉ែត្រ កំពស់ ៣ ម៉ែត្រ ៥០

សង់ទីម៉ែត្រ ហើយត្រូវមានបង្អួចសម្រាប់ខ្យល់ចេញចូលបានផង ទើបមានចំនួនអាកាសល្មមនឹងសេចក្ដីត្រូវការរបស់យើង ។

ហេតុនេះ ក្នុងផ្ទះ យើងត្រូវប្រកាន់តាមកំណត់នេះ ដើម្បីជាគ្រឿងការពារមិនឲ្យរាងកាយទ្រុឌទ្រោមថយកំឡាំងទៅបាន បើយើងមានអាកាសមិនបានចំនួនល្មមគ្រប់គ្រាន់ រោគផ្សេងៗនឹងបៀតបៀនរាងកាយយើងមានជម្ងឺក្អករីងជាដើម ក្រៅពីនេះយើងនៅត្រូវការអាកាសស្អាតបរិសុទ្ធប្រាសចាកគ្រឿងស្មោកគ្រោក ឯគ្រឿងស្មោកគ្រោកមាននៅក្នុងអាកាសតិចច្រើននោះ ស្រេចតែទីកន្លែងនោះៗ ។ ប្រសិនបើមានមនុស្សច្រើនណែនណាន់តាន់តាប់ គ្រឿងស្មោកគ្រោកក្នុងអាកាសក៏មានច្រើន កាលបើយើងដកដង្ហើមចូលទៅនឹងនាំឲ្យកើតទោសដល់រាងកាយយើងមិនខាន ។ ឯវត្ថុជាគ្រឿងស្មោកគ្រោកនោះ គឺមេជម្ងឺ ល្អងធង់ធូលី អាកាសស្មោកគ្រោកដែលដកដង្ហើមចេញមកនឹងផ្សែងបារីជាដើម ។

**មេជម្ងឺឬមេរោគ** — យើងមិនអាចកំចាត់វាចេញឲ្យអស់ទៅបានទេ ព្រោះយើងមើលខ្លួនវាមិនឃើញ ហេតុនេះទើបមានតែវិធីមួយដែលជួយខ្លួនយើងឲ្យរម្ងាប់បាន គឺធ្វើរាងកាយឲ្យមានកំឡាំងខ្លាំងពូកែសម្រាប់តទល់នឹងមេរោគផ្សេងៗ បាន ។

សង់ទីម៉ែត្រ ហើយត្រូវឲ្យមានបង្អួចសម្រាប់ខ្យល់ចេញចូលបានផង ទើបមានចំនួនអាកាសល្មមនឹងសេចក្តីត្រូវការរបស់យើង ។

ហេតុនេះ ក្នុងផ្ទះ យើងត្រូវប្រកាន់តាមកំណត់នេះ ដើម្បីជាគ្រឿងការពារមិនឲ្យរាងកាយទ្រុឌទ្រោមថយកំឡាំងទៅបាន បើយើងមានអាកាសមិនបានចំនួនល្មមគ្រប់គ្រាន់ ពេលផ្សេងៗនឹងបៀតបៀនរាងកាយយើងមានជម្ងឺក្អករីងជាដើម ក្រៅពីនេះយើងនៅត្រូវការអាកាសស្អាតបរិសុទ្ធប្រាសចាកគ្រឿងស្មោកគ្រោក ឯគ្រឿងស្មោកគ្រោកមាននៅក្នុងអាកាសតិចច្រើននោះ ស្រេចតែទីកន្លែងនោះៗ ។ ប្រសិនបើមានមនុស្សច្រើនណែនណាន់តាន់តាប់ គ្រឿងស្មោកគ្រោកក្នុងអាកាសក៏មានច្រើន កាលបើយើងដកដង្ហើមចូលទៅនឹងនាំឲ្យកើតទោសដល់រាងកាយយើងមិនខាន ។ ឯវត្ថុជាគ្រឿងស្មោកគ្រោកនោះ គឺមេជម្ងឺល្អងធូលី អាកាសស្មោកគ្រោកដែលដកដង្ហើមចេញមកនឹងផ្សែងបារីជាដើម ។

**មេជម្ងឺរោគ** – យើងមិនអាចកំចាត់វាចេញឲ្យអស់ទៅបានទេ ព្រោះយើងមើលខ្លួនវាមិនឃើញ ហេតុនេះទើបមានតែវិធីមួយដែលជួយខ្លួនយើងឲ្យរម្ងាប់បាន គឺធ្វើរាងកាយឲ្យមានកំឡាំងខ្លាំងពូកែសម្រាប់តទល់នឹងមេរោគផ្សេងៗបាន ។

ថង់ល្អងធូលី — យើងអាចការពាររបស់ស្មោកគ្រោកអស់នេះបានដោយវិធីខំឧស្សាហ៍បោសសំអាតធូលីលានគ្រឿងប្រើប្រាស់ ពិតានផ្ទះ ជញ្ជាំងផ្ទះ ក្តារក្រាលជាដើមឲ្យស្អាតជានិច្ច ។

អាកាសអាក្រក់ — យើងអាចធ្វើឲ្យទៅជាអាកាសល្អបរិសុទ្ធបាន ដោយវិធីបើកទ្វារបង្អួចឲ្យខ្យល់អាកាសចេញចូលបានដោយស្រួល ។

ផ្សែងបារី — យើងនឹងធ្វើការការពារផ្សែងបារីបានដោយកម្រណាស់ ព្រោះមនុស្សយើងតែងនិយមជក់បារីស្ទើរតែកល់គ្នា យើងនឹងហាមឃាត់មិនឲ្យគេជក់បារីនៅផ្ទះយើងក៏មិនទំនងដែរ ។ ហេតុនេះមានតែផ្លូវមួយ គឺយើងគោងបើកទ្វារបង្អួចឲ្យអស់ហើយយកផ្លិតបក់ផ្សែងបារីចេញឲ្យអស់ ។

## ការសំអាត

ការសំអាត គឺការថែទាំបោសសំអាត និងកំចាត់បង់នូវគ្រឿងស្មោកគ្រោកផ្សេងៗឲ្យអស់ទៅ ដូចជាឧច្ចារៈនិងសម្រាមជាដើម ។

វិធីកំចាត់ឧច្ចារៈ — នៅប្រទេសយើង មានវិធីបន្ទោបង់ឧច្ចារៈបស្សាវៈផ្សេងៗគ្នា មានភូមិខ្លះឬផ្ទះខ្លះប្រើវិធីជីករណ្តៅកប់ឬយកផេះលុបក៏មានវិធីនេះបើធ្វើឲ្យស្អាតហ្មត់ចត់ក៏គួរសមដែរ ទាំងការពារក្លិនឧច្ចារៈមិនឲ្យផ្សាយចេញផង ។ វិធីបន្ទោបង់ឧច្ចារៈក្នុងព្រៃ ឬស្រះបឹង ជាការមិន

គួរគប្បីសោះ ព្រោះអាចនាំឲ្យមានអន្តរាយដល់រាងកាយឬជីវិតរបស់អ្នកដែលប្រើប្រាស់ទឹកអស់នោះបាន ។ បើជាបន្ទប់សាធារណៈដែលមាននៅទីប្រជុំជន មានមនុស្សរាប់រយរាប់ពាន់តែងចេញចូលប្រើប្រាស់នោះត្រូវតែប្រយ័ត្នឲ្យណាស់ ព្រោះថា បើមានអ្នកណាមួយកើតរោគធ្ងន់មានកាមរោគជាដើម មកជុះនៅបន្ទប់នេះ អ្នកក្រោយមកជុះនៅទីនេះទៀតរោគនោះអាចនឹងឆ្លងបាន ។ ទើបឃើញថា បន្ទប់បែបនេះ បើមិនបានថែទាំឲ្យស្អាតល្អទេ មុខគួរឲ្យរង្កៀសពន់ពេក ហេតុនេះទើបត្រូវតែរក្សាទីអង្គុយជុះក្នុងបន្ទប់ឲ្យស្អាតបាតជានិច្ច ត្រូវយកកំណាត់សំពត់ដែលក់ទឹកគ្រេស៊ីលជូត ឬជូតដោយទឹកក្តៅ ត្រូវប្រយ័ត្នកុំបន្ទោបង់បស្សាវៈឲ្យប្រឡាក់ក្តារ ។

(នៅមានត)

គួរគប្បីសោះ ព្រោះអាចនាំឲ្យមានអន្តរាយដល់រាងកាយឬជីវិតរបស់អ្នកដែលប្រើប្រាស់ទឹកអស់នោះបាន ។ បើជាបន្ទប់សាធារណៈដែលមាននៅទីប្រជុំជន មានមនុស្សរាប់រយរាប់ពាន់តែងចេញចូលប្រើប្រាស់នោះ ត្រូវតែប្រយ័ត្នឲ្យណាស់ ព្រោះថា បើមានអ្នកណាមួយកើតរោគឆ្លងមានកាមរោគជាដើម មកដុះនៅបន្ទប់នេះ អ្នកក្រោយមកដុះនៅទីនេះទៀត រោគនោះអាចនឹងឆ្លងបាន ។ ទើបឃើញថា បន្ទប់បែបនេះ បើមិនបានថែទាំឲ្យស្អាតល្អទេ មុខគួរឲ្យរង្កៀសពន់ពេក ហេតុនេះទើបត្រូវតែរក្សាទីអង្គុយដុះក្នុងបន្ទប់ឲ្យស្អាតបាតជានិច្ច ត្រូវយកកំណាត់សំពត់ជ្រលក់ទឹកក្រេសូលជូត ឬជូតដោយទឹកក្តៅ ត្រូវប្រយ័ត្នកុំបន្ទោបង់បស្សាវៈឲ្យប្រឡាក់ក្តារ ។

(នៅមានត)



៤៤— អំពីការសៅសោក ។

# ប្រវត្តិនៃមហាបុរស
# តាំងពីដើមរៀង ៗ មក (តនិងចប់)

## ៤០ — អំប៉ែរ
## (AMPÈRE)

ជាអ្នកប្រាជ្ញជាតិបារាំងសែស អនិច្ចកម្មក្នុងពុទ្ធសករាជ ២.៤២៩ ។ លោកនេះបានរកឃើញការសំខាន់ៗ សម្រាប់គ្រឿងអគ្គិសនី និងបង្ហាញឲ្យឃើញគ្រឿងទូរលេខប្រើទឹកក្រុតជាដំបូង ។

## ៤១ — ឡាអេណេក
## (LAENNEC)

ជាគ្រូពេទ្យជាតិបារាំងសែស អនិច្ចកម្មក្នុងពុទ្ធសករាជ ២.៣៦៩ ។ លោកនេះ គេទទួលកប់ងថាជាអ្នករកឃើញគ្រឿងប្រដាប់សម្រាប់ផ្ទៀងស្តាប់អ្នកជម្ងឺទងដើមទ្រូង ។

## ៤២ — ហ្វ្រេស៍ណែល
## (FRESNEL)

ជាអ្នកប្រាជ្ញជាតិបារាំងសែស អនិច្ចកម្មក្នុងពុទ្ធសករាជ ២.៣៧០ ។ លោកនេះ គេទទួលដឹងថាលោកជាអ្នកប្រឌិតគិតៈធ្វើហ្វារ (ចង្កៀងបញ្ចាំងផ្លូវ) ចំពួកខ្លះ ដែលសម្រាប់ដុះបំភ្លឺទៅតាមមាត់សមុទ្រ ។

## ៤៣ — ហ្វារ៉ាដាយ

(FARADAY)

ជាអ្នកប្រាជ្ញជាតិអង់គ្លេស អនិច្ចកម្មក្នុងឆ្នាំ២.៤១០ នៃពុទ្ធសករាជ ។ លោកនេះបានគេឃើញការយ៉ាងសំខាន់ គឺកូរ៉ង់អេឡេក្ទ្រិក (ខ្សែភ្លើងអគ្គិសនី) ។

## ៤៤ — ហ្វែរឌីណាង់ឌឺឡេស្សិប្ស

(FERDINAND DE LESSEPS)

ជាអ្នកប្រាជ្ញជាតិបារាំងសែស អនិច្ចកម្មក្នុងពុទ្ធសករាជ ២៤៣៧ ។ លោកនេះ គេទទួលរ៉ាប់រងថាជាអ្នកបោះទំលុះព្រែកជីកស៊ុយអេស ។ លោកនេះហើយដែលអនុញ្ញាតឲ្យប្រជាជននានាជាតិធ្វើដំណើរជាចំនួនច្រើនណែនណាន់បំផុត ។

## ៤៥ — ដារវិន

(DARWIN)

ជាអ្នកប្រាជ្ញជាតិអង់គ្លេស អនិច្ចកម្មក្នុងពុទ្ធសករាជ ២.៤២៥ ។ តាមដែលលោកនេះសិក្សាពិនិត្យរកទៅ លោកបង្ហាញឲ្យឃើញថា ក្នុងពួកធម្មជាតិមានការជ្រើសរើសរួមពួករួមក្រុមនីមួយៗ ហើយពួកធម្មជាតិនីមួយៗនោះតែងតទល់គ្នាដើម្បីឲ្យមានជីវិតរស់នៅ ទើបមានការទទួលមត៌កតាមលក្ខណៈនិស្ស័យជាដំណតគ្នារៀងៗមក ។

## ៤៣ — ហ្វារ៉ាដាយ

## (FARADAY)

ជាអ្នកប្រាជ្ញជាតិអង់គ្លេស អនិច្ចកម្មក្នុងឆ្នាំ ២.៤១០ នៃពុទ្ធសករាជ ។ លោកនេះបានរកឃើញការយ៉ាងសំខាន់ គឺក្បួនអេឡេក្ទ្រិក (ក្រសែភ្លើងអគ្គិសនី) ។

## ៤៤ — ហ្វែរឌីណង់ដឺឡេសិប្ស

## (FERDINAND DE LESSEPS)

ជាអ្នកប្រាជ្ញជាតិបារាំងសែស អនិច្ចកម្មក្នុងពុទ្ធសករាជ ២៤៣៧ ។ លោកនេះ គេទទួលព៉ប់រងថាជាអ្នកបោះទំលុះព្រែកជីកស៊ុយអេស៍ ។ លោកនេះហើយដែលអនុញ្ញាតឲ្យប្រជាជននានាជាតិចូលដើរជាចំនួនច្រើនណែនណាន់បំផុត ។

## ៤៥ — ដារវិន

## (DARWIN)

ជាអ្នកប្រាជ្ញជាតិអង់គ្លេស អនិច្ចកម្មក្នុងពុទ្ធសករាជ ២.៤២៥ ។ តាមដែលលោកនេះសិក្សាពិនិត្យរកទៅ លោកបង្ហាញឲ្យឃើញថា ក្នុងពួកធម្មជាតិមានការជ្រើសរើសពូជពួកពូជក្រុមនីមួយៗ ហើយពួកធម្មជាតិនីមួយៗនោះតោងតទល់គ្នាដើម្បីឲ្យមានជីវិតរស់នៅ ទើបមានការទទួលមត៌កតាមលក្ខណៈនិស្ស័យជាដំណតគ្នារៀងៗមក ។

## ៤៦ — ក្លូដ៍ ប៊ែរណារ៍

## (CLAUDE BERNARD)

ជាមហាអ្នកប្រាជ្ញជាតិបារាំងសែស អនិច្ចកម្មក្នុងពុទ្ធសករាជ២៤២១ ។ លោកនេះបានសិក្សាពិនិត្យមើលពួកដំរីថ្លើមនិងសរសៃប្រសាទ ។

## ៤៧ — ប៉ាស្ទ័រ

## (PASTEUR)

លោកនេះជាមហាអ្នកប្រាជ្ញជាតិបារាំងសែស អនិច្ចកម្មទៅកាលពីពុទ្ធសករាជ២.៤៣៨ ។ ដោយហេតុរករកឃើញចំណេះថ្មីៗ ទើបធ្វើឲ្យលោកទៅជាមនុស្សមានឧបការគុណដល់ពិភពលោកនេះ ដោយសារការរកឃើញចំណេះថ្មីៗនេះហើយ មនុស្សយើងទើបមិនមានស្លាប់ដោយជម្ងឺឆ្កែឆ្កួតខាំ ។

ប្រានលី (BRANLY) ជាតិបារាំងសែស កើតក្នុងឆ្នាំ២.៣៨៩ នៃពុទ្ធសករាជ ។

ហែរត្ស៍ (HERTZ) ជាតិអាល្លឺម៉ង់ អនិច្ចកម្មក្នុង ព.ស. ២៤៣៧ ។

ម៉ារកូនី (MARCONI) ជាតិអ៊ីតាលី ស្លាប់ក្នុងពុទ្ធសករាជ២៤៨១ ។

ដោយសារកិច្ចការរបស់លោកទាំង ៣ រូបនេះហើយ ទើបកើតមានវិទ្យុមានខ្សែនិងឥតខ្សែរហូតមកដល់សព្វថ្ងៃនេះ ។

## ៤៨- គ្រាហាំមបែល

(GRAHAM BELL)

ជាអ្នកប្រាជ្ញជាតិអាមេរិកាំង អនិច្ចកម្មក្នុងពុទ្ធសករាជ ២៤៦៥ ។ លោកនេះជាអ្នកគិតប្រឌិតគ្រឿងទូរសព្ទ ព្រមទាំងគ្រឿងបញ្ជូនទំនង គ្រឿងទទួល ។

## ៤៩- អេឌីសុង

(EDISON)

ជាអ្នកប្រឌិតជាតិអាមេរិកាំង អនិច្ចកម្មក្នុងពុទ្ធសករាជ ២៤៧៤ ។ លោកនេះបានកែប្រែហាបភ្លើងឲ្យបានល្អឡើង និងកែប្រែភ្លើងចង្កៀងធ្វើឲ្យមានពន្លឺសល្អឡើង ។

## ៥០- លោកនិងនាងគុយរី

(Monsieur et Madame CURIE)

ប្រុសជាជាតិបារាំងសែស ស្លាប់កាលពីពុទ្ធសករាជ ២.៤៤៩ ។

ស្រីជាជាតិប៉ូឡូណេស៍ស្លាប់កាលពីពុទ្ធសករាជ ២.៤៧៧ ។

ទាំងពីរនាក់នេះជាអ្នកប្រាជ្ញដោយការរកឃើញចំណេះថ្មីតាមផ្លូវវិទ្យាសាស្ត្រ ទុកជាមនុស្សមានគុណឧបការៈដល់មនុស្សលោកផងគ្នា ។ ជីវិតរបស់លោកទុកជាគំរូយ៉ាងមួយដ៏ប្រសើរក្នុងការប្រឹងខ្លាំងចិត្តខ្លាំង

កាកៈធ្វើការងារយ៉ាងម៉ឺងម៉ាត់ហើយប្រកបដោយមេត្តាចិត្ត ជាអ្នកដំកល់ដំកើងការភារៈខ្ពង់ខ្ពស់ជាងមនុស្សក្នុងសម័យយើងសព្វថ្ងៃនេះ ។

## ៥៣ – បងប្អូនលុយមីញែរ៍

**(Les frères LUMIÈRE)**

គេទទួលក៉ប់រងដឹងគុណលោកនេះ ដោយសារតែបានធ្វើកាពយន្ត (កុនឡើងជាដំបូង) ។

# ពុទ្ធប្រវត្តិចិន

(តពីខ្សែ ១០ មក)

## ៤០ — អំពីការបូជាដីខ្សាច់

មានក្មេងម្នាក់កើបដីខ្សាច់១ ក្ដាប់ហើយនាំយកទៅថ្វាយដល់ព្រះពុទ្ធជាម្ចាស់ ។

## ៤១ — អំពីការទទួលបង្ហាន់បុងក្រោយបង្អស់

កាលនាយចុន្ទក្រាបថ្វាយបង្គំទូលអារាធនាព្រះពុទ្ធជាម្ចាស់ឲ្យស្ដេចយាងទៅទទួលចង្ហាន់បិណ្ឌបាតនៅគេហស្ថានរបស់ខ្លួន ។

## ៤២ — អំពីព្រះបច្ឆិមវាចារបស់ព្រះពុទ្ធជាម្ចាស់

នៅវេលាយប់ស្ងាត់ មានពួកសាវកគង់គាល់ជុំវិញព្រះអង្គ ទើបព្រះពុទ្ធជាម្ចាស់ទ្រង់ប្រទានព្រះបណ្ដាំជាបច្ឆិមវាចា ដល់ពួកសាវករបស់ព្រះអង្គ ។

## ៤៣ — អំពីបរិនិព្វាន

នៅវេលាអធ្រាត្រ ព្រះពុទ្ធជាម្ចាស់ស្ដេចទ្រង់ចូលបរិនិព្វាន (ត្រង់នេះខុសគ្នាបន្តិច គម្ពីរហីនយានថា ទ្រង់ចូលបរិនិព្វានក្នុងវេលាជិតភ្លឺ គឺក្នុងវេលាបច្ចូសសម័យ មុនអរុណរះ) ។

## ៤៤ — អំពីការសៅសោក

ស្ដេចចតុលោកបាលចុះមកសៅសោកនៅខាងមុខព្រះបរមសពនៃព្រះពុទ្ធជាម្ចាស់ ។

(មានតទៅទៀត)



អំពីមីលរេប៉ះត្រឡប់ជាមានរូបរាងជាសមណៈប្រា.ជឡើងវិញ ។

# ប្រវត្តិមីលរេប៉ៈ

(តពីខ្សែ ១០ មក)

ឯអ្នកដទៃទៀតនៅផ្ទះប្អូនស្រីនោះ ក៏មានសេចក្ដីជ្រះថ្លានឹងព្រះពុទ្ធ-សាសនានឹងមានជំនឿឡើងទៀតជាច្រើន ៗ ចំណែកខាងឪពុកធំរបស់លោកក៏អនិច្ចកម្មទៅ នៅតែម្ដាយធំក៏បានផ្លាស់ចិត្តគំនិតជាថ្មី ដោយគិតឃើញថា អំពើអាក្រក់ដែលនាងបានធ្វើមកនោះជាបាបទាំងអស់ ទើបនាងចូលទៅរកលោកមីលរេប៉ៈដែលជាក្មួយ ហើយនាងលន់តួសុំទោសចំពោះលោកមីលរេប៉ៈ ហើយនាងគិតនឹងសម្លាប់ខ្លួនឯង តែលោកមីលរេ-ប៉ៈពោលហាមឃាត់មិនឲ្យនាងធ្វើដូច្នោះ ហើយលោកទទួលអត់ទោសឲ្យនាង ហើយលោកបានពន្យល់ខាងផ្លូវសាសនានឹងវិធីប្រតិបត្តិខាងផ្លូវសមាធិ ៗ

លោកមីលរេប៉ៈបានពោលពន្យល់ដល់ពួកសិស្សរបស់លោកថា ខ្លួនលោកបានអប់រំចិត្តគំនិតឲ្យមានកំឡាំងមាំមួនឡើងហើយ នឹងមិនមាននឿយហត់ព្រួយបារម្ភនឹងរាងកាយនេះឡើយ ក្នុងការចេញទៅចំរើនសមាធិក្នុងព្រៃភ្នំក្រមថ្ម ៗ លោកបានទូន្មានពួកសិស្សជាសាវករបស់លោក ដោយវិធីប្រតិបត្តិតាមគំរូរបស់លោក ដើម្បីឲ្យចេះប្រើវិញ្ញាណក្ខន្ធតាមត្រូវការរបស់ខ្លួន ៗ ខណៈនោះមានអ្នកប្រាជ្ញម្នាក់ជាអ្នកមានសេចក្ដីច្រណែន

ៗ „ដំណើរដែលព្រះការពារមហាក្សត្រទ្រង់ធ្លាប់រក្សាទុកនូវព្រះរាជកៀកជាប់ ឲ្យមានអំពើ ការមើលរំលងទុកឲ្យជាប់ឲ្យមាន ដល់ស្រុកខ្មែរ ខាងព្រះ ព្រះមហាក្សត្រស្រុកកម្ពុជតៗគ្នា ហើយបណ្តុះគ្នា„ ហើយ -គង្គកម្មវិធីព្រះរាជលើព្រះមហាក្សត្រ ម្តេចព្រះមហាក្សត្រស្រុកកម្ពុជ ទមហារាជ្យ ព្រះមហាក្សត្រតៗគ្នាទៅ ព្រះមហាទីបរិក្ខារព្រះរាជ មកទុកលក្ខណៈទំនៀមទម្លាប់ ព្រះរាជបញ្ញត្តិទាំងឡាយ ៗ មកដល់សម័យព្រះរាជកម្ពុជា ដូចជាទំនៀមទម្លាប់ ៗ ទំនៀម ទៀតនៅ ខាងក្រោយ ហើយ មកធ្វើនៅទៀត ព្រះរាជាណាចក្រកម្ពុជា មកព្រះរាជព្រះរាជកិច្ចទាំងនេះ ដោយហេតុ ៗ ពីព្រះរាជបរម (គង្គភាព) លក្ខណៈព្រះរាជបញ្ញត្តិ ព្រះរាជពិធី ព្រះរាជការ (គង -ព្រះរាជ) ពីទៀត ហើយ ៗ ការលក្ខណៈ ព្រះមហាក្សត្រ ព្រះរាជការលក្ខណៈ ការនៃព្រះរាជធានី ព្រះរាជការ ទាំងពីរ ព្រះរាជលក្ខណៈ ព្រះមហាក្សត្រ ព្រះមហាក្សត្រ ព្រះរាជពិធីទាំងនេះ ព្រះរាជលក្ខណៈ ព្រះមហាក្សត្រ ៗ ទៀតព្រះរាជ ព្រះមហាក្សត្រ ព្រះរាជការ ពីព្រះរាជ ព្រះរាជ ព្រះរាជ ព្រះរាជ ទំនៀមទម្លាប់ ព្រះមហាក្សត្រ ព្រះរាជពិធី ព្រះរាជការ ព្រះរាជ ព្រះរាជការ ៗ ព្រះមហាក្សត្រ ព្រះរាជ ព្រះរាជ ព្រះរាជ ព្រះរាជ ព្រះរាជការ ព្រះមហាក្សត្រ ព្រះរាជ

គតិនោះមកលោកក៏គង់នៅស្ងៀមមិនកម្រើកខ្លួនទៀតឡើយ រួមអាយុសង្ខាររបស់លោក ៨៤ ឆ្នាំ ក្នុងពុទ្ធសករាជ ១៦៥៨ ក្នុងខណៈដែលព្រះអាទិត្យរះឡើង លោកម៉ីលរេប៉ះក៏ចូលកាន់មរណសញ្ញាស៊ប់ស្ងួន ហើយនៅឱកាសធ្វើពិធីបូជាសពរបស់លោកមានហេតុជាអស្ចារ្យចំឡែកកើតឡើងជាច្រើន ។

ក្នុងខណៈដែលរាងកាយកំពុងត្រូវភ្លើងឆាបឆេះសន្ធោសន្ធៅ ស្រាប់តែឃើញលោកម៉ីលរេប៉ះមានរាងកាយព្រមទាំងស្បង់ចីពរប្រាកដឡើង មានជង្គង់ម្ខាងបត់ក្នុញ ដៃម្ខាងស្ទាបថ្ពាល់ (មើលរូបទំព័រ ៩៤) ហើយពោលគាថាយ៉ាងពីរោះថា :

នៅក្នុងនគរប្រកបដោយកាមទាំង ៦ ជាន់ សុទ្ធតែជាគ្រឿងបំភាន់ចិត្តសត្វលោក ទាំងធ្វើចិត្តគំនិតឲ្យវង្វេងនៅក្នុងគំនរបាបជាច្រើនណាស់ ។

ចិត្តនេះតែងប្រព្រឹត្តទៅតាមអំណាចនៃសេចក្ដីស្នេហាទាំងអាឃាត ហើយមិនមានពេលល្ហមទាំងត្រូវត្រាពិចារណាកិច្ចការទាំងពួងឲ្យយល់ច្បាស់ថាជារបស់មានប្រយោជន៍ ឬឥតប្រយោជន៍ឡើយ ។

បូរអ្នកពលស្នាទាំង្នាព្យាយាមកំចាត់បង់នូវចិត្តអាឃាត

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

ដំណឹងផ្សេងៗក្នុងនានាប្រទេស

# អំពីស្តូបនៅអមរាវតី

កាសែតទេះភ្លើងនៅប្រទេសឥណ្ឌា ចេញផ្សាយកាលពីខែអ៊ិត (ឆ្នាំ ១៩៣៨) មានចុះរឿងព្រះស្តូប "អមរាវតី" ដែលគេរកឃើញនៅខាងត្បូងស្រុកឥណ្ឌា ជិតស្រុកមទ្រដ្ឋ ។

តំបន់នេះមិនមែនមានត្រឹមអនុស្សាវរីយ៍ពុទ្ធសាសនាដែលយើងបានដឹងមកនោះទេ មានទាំងពេជ្រ "កោះអ៊ីនូរ" បែបដែលជាំទឹងមកុដរបស់សម្តេចព្រះរាជិនីអង់គ្លេស ដែលពួកបារាំងសែសបានមើលឃើញ កាលសម្តេចព្រះរាជិនីស្តេចទៅប្រពាតក្រុងប៉ារីស ។

គេស្មានថាពេជ្រ "កោះអ៊ីនូរ" នោះប្រហែលជាបានទៅពីទីតំបន់នេះ ។ អ្នកតែងរឿងចុះកាសែតនោះនិយាយពន្យល់អំពីស្តូបនៅស្រុកអមរាវតី ថាស្តូបអស់នោះសុទ្ធតែមានឆ្លាក់ជាក្បាច់ចេនាផ្សេងៗទាំងស្តូបដែលនៅខាងក្នុងខាងក្រៅរហូតដល់ក្លោងទ្វារក៏មានចេនាដ៏ថ្លៃថ្លា មានអាយុជិតដល់ ២០ សតវត្សរ៍ (គឺ ២.០០០ ឆ្នាំមកហើយ) ។

អស់អ្នកដែលបានទៅមើលឃើញសឹងមានសេចក្តីសរសើរកល់គ្នា ៗ ឯក្បាច់ចេនាអស់នោះមានឆ្លាក់ជារឿងជាតក គឺសិពីជាតក ឃើញមានជញ្ជីងថ្លឹងដុំសាច់របស់ព្រះពោធិសត្វ ដើម្បីជួយសង្គ្រោះសត្វព្រាបមួយ

ញាស្ល ប៉ុនពុនេះទៀតគ្រ ៤ ថ្ងៃទៀតបានបឹងមិនៈទនេះទៅ ដ្បិតយាយ
ទេស លេទឹកគុះគេល ស្រុលុះពៀនដែលហើរមួយសៀលដែលគ្រុលលើ
ប្រទឹងនេះទៀតលក្ខឹកនេះទៀតលម្អក្ខពុតៀល យ ម៉ែយមួយរបស់ទៀតយើងក្តីយ
មិត្តទាំងអស់ ៤ ៈ ប៉ុន្តែកុំទៀតគួរប្រឹងខ្លួនគកាកើតផុលហេតុ ទាំងទើបកុំ
គេអស់ពេលទំនូ «គប្តីស់លេស្រុក» ទន្ទៀកលេលេលពុរផុះទ
ញាក់ប្រលុងអ ញាហ្គមគុំចេញស្រួលមលទឹកប្អូនចុះផលហេតុទៀតសម្លឹង
ពាក្យទៀតមិនបាទថែងលេគ្រ ហេមនុទ្ធទៀតលមគ ដែលគន្ធរបស់មនុស្ស
ៈមនុស្សទឹកផុលទុក ប៉ុនក្រុមទ្ធរង្គស់ ទៅពេញប្រលុងអនុទ្ធទៅទេ
សង្គ្រ ផ្លូវទៅមិនលេពុនេះទៅខ្លួនទៅ ខាងមាយបេប្រទ្ធកុំផ្លងផុត្ត
ទន្ទង់ទៀត ខ្ញុំមិនមួយលេះទៀតយើងទេ ទៅណេះទៀតម៉ឺទូទៅ
៤ ពុលមុលថ្ងៃម្ដងទេនេះទៀតគ្រទោទៀត ។ ខ្ញុំទេលដែលលេ
ឈ្មោះពៅផ្លុំទើបដែលបង្គក្ខផុតញាហ្គ ឡើងហោគេយាកខ្ញុំនេះទៀតពេ
ទៀតនូទន្ទងសុខអខ្មុំ ទៅម៉ែញប្ញុំអើលនេះទៀតឡើងផុះទើបទេមគម
៤ ពិទ្ធនូពុំទើយអ្នកឡើងផុតកើ
ទេ មួយផុតប្រទេសប្រិតឡើងទេគន្ធ ថ្ងៃហបុនអមួយរបស់អក្ខហបយមស់ៀ
ស្រុកកើតយៀតខ្ញុំមិនផ្លេះលទង់ ៤ មុំទេញាកំលុះផុតមុក្ខទៅម៉ីស់ខ្ញុំយ
ៈទៀតលម មួយផុតទើបឧត្ខដើងផុតកើតទេ ៤ មិនដងទ្ទង់ទៀតទយៀតគ្រ

កម្ពុជាបានទទួល ។ សមាគមមហាពោធិនេះតាំងទីសំណាក់ការនៅក្រុង ក័លគុត្តា (Calcutta) មាត់សមុទ្របេងគ័ល (Bengal) ។

នៅកោដ្ឋទី ៣ ដែលដាក់ព្រះសារីរិកធាតុនោះមានជាំពេជ្រដែលមាន ដំឡៃ មានពណ៌ខៀវខ្ចី (មរកត) ដែលគេច្នៃរួចហើយ ។ នៅខាងក្រោយ ព្រះស្តូបដែលបាក់បែកនោះគេបានឃើញក្បាច់ចំឡាក់យ៉ាងល្អឥតជា ច្រើន កន្លែងខ្លះមានឆ្លាក់ជារឿងកាលស្តេចក្រុងមារលើកពលមកផ្ចាញ់ ព្រះ ហើយមានក្បាច់ ១ ពួកទៀត ឆ្លាក់ជារឿងសសជាតក កាលព្រះ សម្ពុទ្ធយោនយកកំណើតជាសត្វទន្សាយហើយបានបងមេត្រីនឹងស្វា ១ ឆ្កែ ចចក ១ កេ ១ ឃើញរូបមហាសត្វ (ទន្សាយ) នោះបរិច្ចាគជីវិតលោត ទៅក្នុងភ្លើង ។

មានបែបចម្លាក់ចេនាជាច្រើននៅអមរាវតីនោះ ក្នុងវេលានេះឃើញ មានដាក់តាំងនៅក្នុងពិពិធភណ្ឌស្ថានក្រុងឡុនដុនជាទីក្រុងនៃប្រទេសអង់ គ្លេស នឹងពិពិធភណ្ឌស្ថាននៅស្រុកមទ្រដ្ឋ ។

ក្នុងបច្ចុប្បន្ននេះ គេបានដឹងថា នៅប្រទេសខាងត្បូង មិនមានអ្នក កាន់ព្រះពុទ្ធសាសនាទេ ទើបគេប្រមូលយកគ្រឿងចម្លាក់ចេនាដែលល្អថ្លៃ ថ្លាអស់នេះទៅទុកដាក់ក្នុងសារមន្ទីរមិនឲ្យវិនាសខូចខាតហើយអនុញ្ញាត ឲ្យសាធារណជនទូទៅ ចូលទៅមើលបែបសិល្បកម្មពុទ្ធសាសនាបាន ពល់គ្នា ។

# ប្រជុំពាក្យកាព្យ

## ភាគទី ៤

*របស់កៀកិមៀ ( អួន )*

( នៅមានត )

បង្អៀតដូចម្ដេចគេចកែកល់
ទៅដល់មិនហ៊ានខានឡើយនៃ ។
ឥឡូវរៀមរកនិត្យនៅទីណ៎
ឥតមានទីពឹងពាក់ប្រស្រ័យ
តែនឹកគិតព្រួយចិត្តតែសព្វថ្ងៃ
ក្រែងមនុស្សប្រែធ្រក់ពាក្យបាច ។
ខុសម្ដេចតាមតែមេត្តាផង
កុំឲ្យរៀមនេះទុក្ខដល់ខ្លាត
ឲ្យមានតែក្ដីទីអនុញ្ញាត
សង្វាតនឹងបានដូចប្រាថ្នា ។

## រ៉ក្សាភិរម្យ (អ្លួង)

• ហ៊ុមព្រែ មហាតន្ត្រីក នៃព្រះករុណា ព្រះបាទសម្ដេចព្រះនរោត្តម

ឱះឱកម្មអនិច្ចា

ទុក្ខវេទនានេះខ្លួនអើយ

កាលណាទើបបានស្បើយ

ទីងល្ហៃល្ហើយក្តីអំពល់ ។

អំពើធ្វើពីព្រេង

នោះវាតែងឲ្យគង្វល់

ក្តួចក្តាំងស្តុតស្តាំងសល់

ព្រោះតែកម្មនាំមក ។

ឲ្យព្រួយចិត្តចំបែង

ទុក្ខតែងគ្រាំគ្រៀមគក

រកោះគន់គិតរក

ពុំបានជួបក្តីប្រាថ្នា ។

ពឹងបុណ្យៗ ពុំជួយជូន

កម្មមកជួនផ្តល់អាត្មា

បើបោះតើអ្នកណា

ជួយជំរះគន់មេត្រី ។

ឲ្យបានស្រាន្តទុក្ខា

កុំឲ្យអសារសេចក្តី

ដ្បិតទល់ទុក្ខណាស់នៃ
ស្មើរប្រេះបែកឧកាអើ ៗ
អ្នកទាំងឡាយគេក៏មាន
ទុក្ខក្ដីប្រាណដូចគ្នាហោង
តែគ្រាន់បើបានសាសង
សាសម្នេះទៅមកបាន ៗ
តែខ្ញុំនេះម្ដងឡើយ
ផ្ញើរម្ដងអើយក៏នឹងបាន
ស្រាកស្រាន្តចិត្តគិតឡើក្រន្ត
គិតសព្វគ្រប់ថប់ធ្វើសធ្វើ ៗ
ប្រាសប្រាណប្រែម្ដងហៅស្គាល់
វិវេកចិត្តក្នុងមណ្ឌល
ព្រួយអំពល់ដោយអាល័យ
ញ្ញើរចំប្រប់សព្វសារសែ ៗ
ធរណីអាកាសា
ឆ្ងាយពីគ្នាគួរណាស់នៃ
ឯខ្ញុំនរៀមនឹងប្អូនថ្លៃ
កើតនៅដីដែនពសុធា ៗ

# បំណែកខេមរជាតិក្នុងប្រទេសថៃឡង់ដ៍

របស់លោកពីយែរអង់ដែល

ក្នុងសម័យថ្មីៗនេះ យើងដឹងថា រាជការក្រុងបាងកក បានសម្រេចផ្លាស់ឈ្មោះប្រទេសរបស់គេជាថ្មី គឺផ្លាស់ឈ្មោះ " សៀម ជាថៃឡង់ដ៍ " វិញ ។

ការកែប្រែថ្មីនេះ ឥតមានទោសពៃរ៍អ្វីទេ គ្រាន់តែបិទបាំងគំនិតលាក់លៀបនៃប្រសាសនោបាយរបស់ប្រទេសមិនជិត ។

ឯជនជាតិសៀមនេះ តាមពូជពង្សជាពួកជាតិថៃ ប៉ុន្តែពួកថៃខ្វ-ទៅនោះ មិនមែនជាជាតិសៀមទេ ។ ការតាំងឈ្មោះប្រទេសសៀមជាថ្មីនេះ ជាគំនិតមួយធ្វើឲ្យមានទំនងក្នុងការបន្ទំឈ្មោះទាំងពីរនេះដើម្បីបង្កហេតុប្រកាសទាមទារទឹកដី ដូចយើងបានឃើញហេតុកើតជាដំបូងក្នុងសម័យនេះ ។

ជាតិថៃបែកផ្សាយចេញទៅពីសពាស តាំងអំពីស្រុកឆានទៅប្រទេសភូមាទៅដល់ស្រុកចិនខាងត្បូង ដោយដើរកាត់ស្រុកសៀមខាងក្រោម ស្រុកលាវ-សៀម ស្រុកលាវ-បារាំងសែស ព្រមទាំងស្រុកតុងកឹងខាងលើ ទិនឆ្នេរទន្លេខ្មៅ ។ ពិនិត្យតាមនេះទៅ ឃើញថាជាតិថៃហៀរហូរបែកផ្សាយចេញក្រៅអំពីដែនដីសៀមឆ្ងាយណាស់ ត្រង់នេះហើយដែលប្រទេសសៀមចង់បំភ្លេចចោល ។

ការតក់នៃក្រុងបាងកកគ្រានេះ គ្រាន់តែតក់ចំពោះប្រទេសឥណ្ឌូស៊ីនស៊ិនទេ សេចក្ដីតក់នោះសោតទៀត ក៏ត្រូវកដការបារាំងសែសផាត់ទាត់ចោលយ៉ាងស្រឡះទៅហើយ ចំណែកខាងប្រជាជាតិដែលខ្លួនគិតកៀរប្រមូលទៅនោះ ក៏បានសំដែងទឹកចិត្តស្មោះស្ម័គ្រ ស៊ូនៅតែក្នុងចំណោមប្រទេសឥណ្ឌូស៊ីនបារាំងសែស ដូចជាការលើកគ្នាហៃហមដ៏ឧឡារិកសំដែងមេត្រីចិត្តនៃប្រជាជនទាំងនោះស្រាប់ ដល់ម៉្លោះទៅហើយ វិទ្យុនឹងការសែតផិតខាងក៏នៅតែហ៊ានទទូចស្រែកបញ្ជាក់យ៉ាងអឹកធិកដោយសំដីរើករាយផ្ដេសផ្ដាស គឺថាគេអាចនិយាយបានខ្លះតែត្រឹមប៉ុណ្ណឹងទេ ។

ប៉ុន្តែក្នុងការប្រកាសឆ្លងឆាងថ្មីៗរបស់ថៃឡង់ដ៏នោះ នៅមានក្លេបក្លាំងរើករាយជាច្រើនអំពីលក្ខណៈនៃមនុស្សជាតិនីមួយៗ ដូចមានសេចក្ដីខាងក្រោមនេះជាដើមៈ

បើនឹងនិយាយអំពីលក្ខណៈមនុស្សជាតិក្នុងលោកនេះ មិនមានប្រទេសណាដែលនឹងនិយាយបាន ដោយលំបាកជាងប្រទេសថៃឡង់ដ៏ ។ ក្នុងចំនួនជនជាតិថៃឡង់ដ៏ ១២ លាន គេកប់ទៅឃើញមានកូនកាត់ចិន ៤ លានទៅហើយ ប្រទេសដែលមានប្រជាជននានាជាតិលាយឡំដល់

១ ភាគក្នុង ៣ ភាគទៅហើយ ។ ចេញប្រកាសអំពីលក្ខណៈរបស់មនុស្ស-ជាតិដូច្នោះនេះ ជាការដែលគេមិនធ្លាប់ដឹងឮទេ ។

* * *

ណ្ហើយចុះ យើងទុកជាពួកកូនកាត់ចិនជាជាតិសៀមទាំងអស់ទៅចុះ ក្រៅពីនេះទៅ នៅមានជនជាតិចិនសុទ្ធជាងកន្លះលានទៅទៀត (៥២៥.០០០) មានពួកម៉ាឡាយូ ៤០០.០០០ នាក់នៅក្នុងខែត្រខាងត្បូងនៃជ្រោយដីថៃឡង់ដ៍ ដូចជានៅ ប៉ាតតានី, យឡា, នពធិវាស និង សិង្គូរ៉ ។ ខ្ញុំដឹងហើយ ពាក្យដែលរដ្ឋការថៃប្រើសម្រាប់ហៅពួកម៉ា-ឡាយូនោះ ដោយសំដីសុភាពផ្អែមថា "ថៃ-អ៊ិស្លាម" ប៉ុន្តែទុកជាហៅដូច្នេះក៏ដោយ ក៏មិនអាចធ្វើឲ្យពួកម៉ាឡាយូនោះ ទៅជាមិនមែនម៉ាឡា-យូបានឡើយ ។ កាលមុនឆ្នាំ ១៩០៩ ជនជាតិម៉ាឡាយូនេះ នៅមានចំនួនច្រើនជាង ១ លាននាក់ ម្តេចឡើយប្រទេសថៃឡង់ដ៍ក្នុងសម័យនោះក៏ត្រូវផ្តាច់ផែនដីខ្លះ បញ្ចូលទៅក្នុងដីម៉ាឡាយូអង់គ្លេស គឺខែត្រកេដា, កឡង់តាន់, ត្រាំងកានូ, ប៉ឺលិស ។ ប្រសិនបើខ្ញុំបានធ្វើជាគូវែរ-ណើរសេ៊ណេរ៉ាល់លើដីចំណុះអង់គ្លេសនោះ ខ្ញុំនឹងធ្វើឲ្យពួកអ្នកនៅក្រុងបាងកក ដែលក្តៅក្រហាយទារកៃប្រទឹកដីទាំងនោះ ឲ្យស្រាយចិត្តមិនបាន ណ្ហើយចុះ មិនបាច់និយាយទទូចតទៅទៀតទេ ។

នៅទីបំផុត មានជាតិខ្មែរចំនួន ៤៤០.០០០ នាក់ បើបូករួមជាតិផ្សេងៗនៅក្នុងថៃឡង់ដ៍ ឃើញថាមានចំនួន ១.៣៧៨.០០០ នាក់ ត្រូវជាចំនួនលើសពី ១ ភាគក្នុង ១០ ភាគរបស់ប្រជាជននៅប្រទេសថៃឡង់ដ៍ទាំងមូល ។ ប្រសិនបើយើងបន្ថែមពួកកូនកាត់ចិនចូលក្នុងចំនួនជនជាតិដទៃផងនោះ នឹងឃើញថាវិធីលក្ខណៈមនុស្សជាតិរបស់ថៃឡង់ដ៍ មានទ្រង់ទ្រាយប្លែកពីគេណាស់ ។

* * *

ការដែលនិយាយពីជាតិចិន ជាតិម៉ាឡាយូ ដែលនៅក្នុងថៃឡង់ដ៍ យើងឥតត្រូវការទេ ប៉ុន្តែយើងត្រូវការនិយាយចំពោះស្រុកខ្មែរប៉ុណ្ណោះ ដ្បិតស្រុកខ្មែរជាស្រុកដែលអ្នកជិតខាងយើងយកចិត្តទុកដាក់ជាទីបំផុត ។

ក្នុងកាសែតឥណ្ឌូស៊ីនចុះថ្ងៃ ៧ ណូវ៉ែម្ប្រនេះ បានផ្សាយសេចក្ដីមួយយ៉ាងពីរោះរបស់លោកកម្មបុត្រ ដែលលោកបានប្រកាសបញ្ជាក់ថា ជនជាតិខ្មែរសុខចិត្តនៅតែជាខ្មែរ មិនចង់លាយឡំនឹងជាតិថៃទេ ។ ក្នុងពេលណាដែលក្រុងបាងកកចង់បានដីណាវនោះ ក៏បញ្ចេញវិធីលក្ខណៈមនុស្សជាតិយកមកនិយាយ ខាងឯស្រុកខ្មែរវិញ ក៏និយាយសំអាងដោយរបៀបផ្សេងទៅវិញ ។ ចំណែកខាងយើង ប្រសិនបើយើងត្រូវការយកវិធីលក្ខណៈមនុស្សជាតិមកនិយាយផងនោះ យើងត្រូវតែគាំទ្រយក

ដីដែលជនជាតិខ្មែរនៅទាំងប៉ុន្មានក្នុងប្រទេសថៃ បញ្ចូលមកក្នុងក្រុងកម្ពុជាវិញទើបត្រូវ ។ ប៉ុន្តែយើងមិនរវល់ទៅតក់ទាមទារអំពីអ្នកណាទេ ដ្បិតយើងគ្មានបំណងចិត្តទៅដណ្តើមយកទឹកដីរបស់គេឡើយ គឺថាបើប្រសិនណាជាយើងត្រូវការតក់ មិនមែនជាយើងគ្មានគោលចារិកជាសំអាងនោះទេ ។

ជនជាតិខ្មែរដែលមានចំនួនច្រើនក្នុងប្រទេសថៃ គឺមាននៅតាមប្រទល់ដែនខាងជើងនៃក្រុងកម្ពុជា ខាងកើតទឹងអគ្នេយ៍ស្រុកគោកក៉ត ខាងលិចទឹងទិសនិរតីស្រុកឧប្បល ទឹងតាមបន្ទោះភ្នំដងរែកទឹងទន្លេណាមមូន (យើងត្រូវតែសំគាល់ថាឈ្មោះ គោកក៉ត គឺឈ្មោះដែលខ្មែរហៅថាអង្គកជទុះឯង ដែលសៀមយកមកបង្រួញឲ្យខ្លីទៅ ។ ឯឈ្មោះណាមមូននោះសោតទៀត ក៏ជាឈ្មោះចាស់របស់ខ្មែរដែលហៅថា ស្ទឹងព្រមូល) ។

នៅខាងត្បូងខេត្តសុរិន្ទ បុរីរំ និងគោកខណ្ឌ ពួកអ្នកស្រែចំការសឹងសុទ្ធតែជាជាតិខ្មែរទាំងអស់ ។ នៅលើខ្នងភ្នំដងរែកមានជាតិខ្មែរស្តួចស្តើងទេ តែដីទំនាបពីជើងភ្នំដងរែកទៅតាមដងទន្លេណាមមូនដែលជាទីធ្វើស្រែចំការបាននោះមានខ្មែរកុះករជាច្រើន ។ អាណាចក្រនេះសោតទៀត ក៏បានធ្វើបុកណស្ថានទុកជាគ្រឿងដំណែលយ៉ាងច្រើនដល់១ភាគក្នុង ៣ ភាគក្នុងផែនដីថៃទិសខាងកើតហេតុដល់សព្វថ្ងៃនេះ ដែលអាណាចក្រខ្មែរធ្លាប់ទុកជាផ្លូវធ្លាមួយមកជាចំនួនច្រើនសតវត្សរ៍ ។ សព្វថ្ងៃនេះ គេនៅ

ឃើញកន្លែងណាល្អ ផ្លូវគមនាគម ស្រះទឹក នឹងបុកណាស្ពាន ១០៩ អន្ទើ ជារបស់ខ្មែរនៅដីថៃ ។

នៅមានជនជាតិខ្មែរ ១ ក្រុមធំទៀត ដែលសៀមកៀរប្រមូលយកទៅបំពេញស្រុកនោះ សព្វថ្ងៃនេះ នៅក្នុងស្រុក រាជបុរី កាញ្ចនបុរី បាន-ខ្មែរ សុពណ៌បុរី ព្រះបាទ នគរនាយក កំសារត្រាម នគរស្រីជ័យ ស្រីមហាបព្វត បាងកកហ្ស៊ឺងឯង ព្រមទាំងពួកជនដែលនៅបន្ទោះក្រុងបាងកក នឹងបាចិនបុរី សឹងសុទ្ធតែជាជាតិខ្មែរទាំងអស់ ជនជាតិខ្មែរទាំងនុះហើយដែលត្រូវសៀមកៀរយកពីស្រុកខ្មែរទៅ កាលពីសង្គ្រាមឆ្នាំ ១៨១១-១៨៣៣-១៨៤៦ យកទៅឲ្យកាប់ឆ្ការដីព្រៃនៅមាត់ពាមទន្លេមែណាមធ្វើឲ្យទៅជាដីស្រែបំរើនផលព្រះធរណី ដែលជនជាតិសៀមគ្មានចិត្តខ្នះខ្នែងនឹងធ្វើនឹងបំពេញផលដីរបស់ខ្លួនបាននោះ (ត្រង់ឈ្មោះស្រុកថា បាចិនបុរី នេះ ក្លាយមកពីពាក្យថា បស្ចិមបុរី ប្រែថាស្រុកទិសខាងលិចនៃដែនកម្ពុជា សៀមយកទៅប្រែថា បាចិនបុរី ប្រែថាស្រុកទិសខាងកើតវិញ មើលតែការកែប្រែបន្តិចបន្តួចប៉ុណ្ណោះ ក៏ល្មមដឹងដល់គំនិតរបស់ថៃហើយ) នៅមានខ្មែរ ២ ក្រុមទៀត មានចំនួនតិចបន្តិចនៅត្រង់បន្ទោះដីអរញ្ញនឹងបាចិនបុរី នឹងតាមឆ្នេរទន្លេដែលថៃហៅថាណាមមុនមួយកំណាត់ខាងលើនៃស្ទឹងមន្តលបុរី ដែលហូរចុះមកក្នុងទន្លេសាប ។

* * *

រដ្ឋការនៅក្រុងបាងកក មានគំនិតគិតតែបន្ថយចំនួនជាតិដទៃដែលនៅក្នុងថៃឡង់ដ៏ឲ្យឃើញមានតិច កាលពីឆ្នាំ ១៩៣០ ក្រសួងពាណិជ្ជ-ការនិងគមនាគមផ្សាយដំណឹងថា ខ្មែរនៅប្រទេសថៃឡង់មានចំនួន ១៦០.០០០ នាក់ ។

ដល់មកឆ្នាំ ១៩៣៩ កាសែតស្យាមនិក្ខេសនៅក្រុងបាងកកផ្សាយដំណឹងថា ប្រជាជនក្នុងខេត្តសុរិន្ទមួយ មានចំនួន ៣៣៩.០០០ នាក់ ក្នុងចំនួននេះមានខ្មែរ ១ ភាគក្នុង ៣ ភាគ នៅខាងស្រុកគោកខណ្ឌ (២៤០.០០០ នាក់) និងបុរីរាំ (៣៦០.០០០ នាក់) និងខាងត្បូងនៃឆ្នេរទន្លេណាមមូនដែលមានសុទ្ធតែជនជាតិខ្មែរ តែអ្នកកែងកាសែតមិននិយាយដល់សោះ ខ្មែរនៅតំបន់អស់នេះក៏មានចំនួន ១ ភាគក្នុង ៣ ភាគដែរ ។ ពិនិត្យតាមទំនងនេះទៅ ឃើញថាជនជាតិខ្មែរនៅត្រឹមតែខាងជើងភ្នំដងរែក ១ នោះ មានចំនួន ៣១៤.០០០ នាក់ទៅហើយ ។

បើតាមចំនួនដែលលោកគ្រាហាំម បានសរសេរទុកក្នុងសៀវភៅរបស់លោកថា ជនជាតិខ្មែរមានចំនួន ៤៥០.០០០ នាក់នៅក្នុងប្រទេសថៃ ពាក្យនេះក៏ឃើញថាគួរល្មមនឹងជឿបាន ។

ជនជាតិខ្មែរទាំងនោះ បានរក្សាទុកនូវប្រពៃណីសឹងបានទាំងអស់ គឺភាសា, ទំនៀមទម្លាប់ និងកិរិយាមារយាទដែលជាគ្រឿងសំគាល់របស់ជាតិនីមួយៗ ។ ប៉ុន្តែពពួកខ្មែរនោះ ឥតមានសាលារៀនមួយសម្រាប់

ពួកខ្លួនសោះ ដ្បិតជាតិថៃត្រូវការបង្រួបជាតិផ្សេងៗឲ្យទៅជាថៃ តាំងអំពីកាលដែលជនជាតិទាំងនោះនៅក្នុងខ្វីសេចក្ដីបេះដូង ។ តាំងអំពីរដ្ឋផុតពីការបលាបលឆ្នាំ ១៩៣២ មក គោលគំនិតរបស់រាជការថៃគឺគិតតែរៀបចំបង្រៀនដូចម្ដេចឲ្យខាងតែកុមារប្រុសស្រី ក្មេងបាត់ទឹកដល់ជាតិសាសន៍របស់ខ្លួនប៉ុណ្ណោះ ។ សាលាបង្រៀននៅទីវត្តតាំងប៉ុន្មានដែលជាការមិនត្រូវតាមបំណងប្រសាសនោបាយថៃឡូងដ៏ នោះរាជការថៃលុបចោលទាំងអស់ ឯក្រសួងកម្ពុជាវិញ រាជការបារាំងសែសខំប្រឹងប្រែងរៀបចំធ្វើឲ្យបានចំរើនខាងការសិក្សាសាលាវត្ត ។ កិច្ចការទាំងនោះក៏មិនអាចនឹងធ្វើឲ្យខ្មែរដែលនិយាយភាសាថៃប្រើខ្យល់ថៃឲ្យច្បាស់បានឡើយ គ្រាន់តែហាមាត់និយាយក៏ដឹងថាជាខ្មែរ ១ រំពេច ។ ឯជនជាតិខ្មែរ ដែលនៅខាងជើងខ្នងភ្នំដងរែកនោះ តែងតែប្រើភាសាជាន់ចាស់របស់ខ្លួនជារៀងរាបដរាបមក និយាយប្រើខ្យល់ខ្មែរច្បាស់លាស់ជាងខ្មែរនៅស្រុកខ្មែរនេះទៅទៀត ខ្យល់ខ្មែរប៉ុណ្ណេះហើយដែលជាគ្រឿងសំដែងឲ្យឃើញថា ជនជាតិខ្មែរនៅទីនុះបេះទប់ទល់អាត្មាជាដរាប មិនឲ្យជ្រុលទៅតាមគំនិតដែលគិតធ្វើខ្លួនឲ្យទៅជាសៀមនោះ ។

រឿងនេះធៀបដូចជាភាសាបារាំងសែស ដែលជាតិបារាំងសែសយកទៅប្រើនិយាយនៅកាណាដា ជាវេលាយូរឆ្នាំមកហើយ ។ នៅតែមានខ្យល់ពីកោះពិសាដរាបមកដល់សព្វថ្ងៃនេះ ។ អម្បាលយ៉ាងខ្មែរនៅ

ប្រទេសថៃម៉េចគង់មិនពាន់សុខចិត្តយល់ព្រមឲ្យគេបង្វែរខ្លួនជាថៃនោះទៅហើយ ចំណាន់បើជនជាតិខ្មែរដែលនៅក្រុងកម្ពុជានេះ ធ្វើម្តេចឡើយទឹងសុខចិត្តធ្វើខ្លួនឲ្យទៅជាថៃ ។ ហេតុនេះហើយបានជាយើងត្រូវតែដឹងថាខ្មែរនៅស្រុកខ្មែរខំតក់យ៉ាងម៉ឺងម៉ាត់ ធ្វើដូចម្តេចឲ្យអាងតែបានខ្មែរនៅជាខ្មែរ - បាកំងសែសដោយដាច់ខាត ។